

ឯកសារគម្ពីរព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កានដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ផុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ួច សាវៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ុវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ដឹម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ផែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទួត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ស៊ែ សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ដុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា វ៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហួ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្ដីប្រែជាភាសាខ្មែរ
# អភិធម្មបិដក
# វិភង្គ ទុតិយភាគ
# ៨១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០៨

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្ចង់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku

ប្រធានការិយាល័យ The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi It
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未會有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

| | | | | |
|---|---|---|---|---|
| 世話人代表 | 無着　成恭 | 世話人 | 松永　然道 | 有馬　実成 |
| 事務局長 | 篠原　鋭一 | | 伊藤　佳通 | 渡井　奎一 |
| | | | 杉谷　義純 | 茂田　真澄 |
| | | | 前田　利勝 | 中島　教之 |
| | | | 永　六輔 | |

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# អភិធម្មបិដក

## វិភង្គ ទុតិយភាគ

៨១

ព.ស. ២៥០៨

# អភិធម្មបិដកេ

## វិភង្គស្ស ទុតិយោ ភាគោ

---

## បច្ចយាការវិភង្គោ

(១) អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២) តត្ថ កតមា អវិជ្ជា ។ ទុក្ខេ អញ្ញាណំ ទុក្ខសមុទយេ អញ្ញាណំ ទុក្ខនិរោធេ អញ្ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ អញ្ញាណំ អយំ វុច្ចតិ អវិជ្ជា ។

# អភិធម្មបិដក

## វិភង្គ ទុតិយភាគ

## បច្ចយាការវិភង្គ

[ ១ ] សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈ កើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

[ ២ ] បណ្តាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្តេច ។ ការមិនដឹងកងទុក្ខ ការមិនដឹងកងហេតុជាទីកើតឡើងនៃទុក្ខ ការមិនដឹងកងធម៌ជាទីរលត់ទៅនៃទុក្ខ ការមិនដឹងកងបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ នេះហៅថា អវិជ្ជា ។

(៣) តត្ថ កតមេ អវិជ្ជាបច្ចយា សង្ខារា ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ កាយសង្ខារោ វចីសង្ខារោ ចិត្តសង្ខារោ ។ តត្ថ កតមោ បុញ្ញាភិសង្ខារោ ។ កុសលា ចេតនា កាមាវចរា រូបាវចរា ទានមយា សីលមយា ភាវនាមយា អយំ វុច្ចតិ បុញ្ញាភិសង្ខារោ ។ តត្ថ កតមោ អបុញ្ញាភិសង្ខារោ ។ អកុសលា ចេតនា កាមាវចរា អយំ វុច្ចតិ អបុញ្ញាភិសង្ខារោ ។ តត្ថ កតមោ អានេញ្ជាភិសង្ខារោ ។ កុសលា ចេតនា អរូបាវចរា អយំ វុច្ចតិ អានេញ្ជាភិសង្ខារោ ។ តត្ថ កតមោ កាយសង្ខារោ ។ កាយសញ្ចេតនា កាយសង្ខារោ វចីសញ្ចេតនា វចីសង្ខារោ មនោសញ្ចេតនា ចិត្តសង្ខារោ ។ ឥមេ វុច្ចន្តិ អវិជ្ជាបច្ចយា សង្ខារា ។

(៤) តត្ថ កតមំ សង្ខារបច្ចយា វិញ្ញាណំ ។ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ មនោវិញ្ញាណំ ឥទំ វុច្ចតិ សង្ខារបច្ចយា វិញ្ញាណំ ។

[ ៣ ] បណ្ដាបច្ចយាការទាំងនោះ សង្ខារទាំងឡាយ កើតមាន
ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ
អានេញ្ជាភិសង្ខារ កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ ។ បណ្ដាសង្ខារ
ទាំងនោះ បុញ្ញាភិសង្ខារ តើដូចម្ដេច ។ ចេតនាជាកុសល ជាកា-
មាវចរ និងរូបាវចរ ដែលសម្រេចដោយទាន សម្រេចដោយសីល
សម្រេចដោយភាវនា នេះហៅថា បុញ្ញាភិសង្ខារ ។ បណ្ដាសង្ខារទាំង
នោះ អបុញ្ញាភិសង្ខារ តើដូចម្ដេច ។ ចេតនាជាអកុសល ជាកាមាវ-
ចរ នេះហៅថា អបុញ្ញាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ អា-
នេញ្ជាភិសង្ខារ តើដូចម្ដេច ។ ចេតនាជាកុសល ជាអរូបាវចរ
នេះហៅថា អានេញ្ជាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ កាយសង្ខារ
តើដូចម្ដេច ។ កាយសញ្ចេតនា ឈ្មោះថា កាយសង្ខារ វចីសញ្ចេ-
តនា ឈ្មោះថា វចីសង្ខារ មនោសញ្ចេតនា ឈ្មោះថា ចិត្តសង្ខារ ។
ធម៌ទាំងនេះ ហៅថា សង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

[ ៤ ] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះ
សង្ខារជាបច្ច័យ តើដូចម្ដេច ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃា-
នវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ នេះហៅថា
វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

(៥) តត្ថ កតមំ វិញ្ញាណបច្ចយា នាមរូបំ ។ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនា សញ្ញា ចេតនា ផស្សោ មនសិការោ ឥទំ វុច្ចតិ នាមំ(១) ។ តត្ថ កតមំ រូបំ ។ ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយ រូបំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ វិញ្ញាណបច្ចយា នាមរូបំ ។

(៦) តត្ថ កតមំ នាមរូបបច្ចយា សឡាយតនំ ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ឥទំ វុច្ចតិ នាមរូបបច្ចយា សឡាយតនំ ។

(៧) តត្ថ កតមោ សឡាយតនបច្ចយា ផស្សោ ។ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កាយសម្ផស្សោ មនោសម្ផស្សោ អយំ វុច្ចតិ សឡាយតនបច្ចយា ផស្សោ ។

---

១ ឱ. ម. តត្ថ កតមំ នាមំ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមន្តិ ឥមេ បាឋា ទិស្សន្តិ ។

( ៤ ) បណ្ដាបច្ចយាការទាំងនោះ នាមរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាមនិងរូបនោះ នាម តើដូចម្ដេច ។ វេទនា សញ្ញា ចេតនា ផស្សៈ មនសិការៈ នេះហៅថា នាម ។ បណ្ដានាមនិងរូបនោះ រូប តើដូចម្ដេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតទាំង ៤ នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។

( ៦ ) បណ្ដាបច្ចយាការទាំងនោះ សឡាយតនៈ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ តើដូចម្ដេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ មនាយតនៈ នេះហៅថា សឡាយតនៈ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។

( ៧ ) បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ តើដូចម្ដេច ។ ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស នេះហៅថា ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ ។

(៨) តត្ថ កតមា ផស្សបច្ចយា វេទនា ។ ចក្ខុសម្ផស្សជា វេទនា សោតសម្ផស្សជា វេទនា ឃានសម្ផស្សជា វេទនា ជិវ្ហាសម្ផស្សជា វេទនា កាយសម្ផស្សជា វេទនា មនោសម្ផស្សជា វេទនា អយំ វុច្ចតិ ផស្សបច្ចយា វេទនា ។

(៩) តត្ថ កតមា វេទនាបច្ចយា តណ្ហា ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា អយំ វុច្ចតិ វេទនាបច្ចយា តណ្ហា ។

(១០) តត្ថ កតមំ តណ្ហាបច្ចយា ឧបាទានំ ។ កាមុបាទានំ ទិដ្ឋុបាទានំ សីលព្វតុបាទានំ អត្តវាទុបាទានំ ឥទំ វុច្ចតិ តណ្ហាបច្ចយា ឧបាទានំ ។

(១១) តត្ថ កតមោ ឧបាទានបច្ចយា ភវោ ។ ទុវិធេន ភវោ អត្ថិ កម្មភវោ អត្ថិ ឧបបត្តិភវោ ។ តត្ថ កតមោ កម្មភវោ ។ បុញ្ញាភិសង្ខារោ អបុញ្ញាភិសង្ខារោ អានេញ្ជាភិសង្ខារោ អយំ វុច្ចតិ កម្មភវោ សព្វម្បិ ភវគាមិកម្មំ កម្មភវោ ។

( ៨ ) បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ វេទនា កើតអំពីចក្ខុសម្ផ័ស្ស វេទនា កើតអំពីសោតសម្ផ័ស្ស វេទនា កើតអំពីឃានសម្ផ័ស្ស វេទនា កើតអំពីជិវ្ហាសម្ផ័ស្ស វេទនា កើតអំពីកាយសម្ផ័ស្ស វេទនា កើតអំពីមនោសម្ផ័ស្ស នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។

( ៩ ) បណ្ដាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា នេះហៅថា តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ។

( ១០ ) បណ្ដាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្ដេច ។ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

( ១១ ) បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្ដេច ។ ភពមាន ២ គឺកម្មភពក៏មាន ឧបបត្តិភពក៏មាន ។ បណ្ដាភពទាំងនោះ កម្មភព តើដូចម្ដេច ។ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ នេះហៅថា កម្មភព សូម្បីកម្មទាំងអស់ ដែលជាដំណើរទៅកាន់ភព ក៏ឈ្មោះថា កម្មភពដែរ ។

## បច្ចយាការវិភង្គេ សុត្តន្តភាជនីយំ

តត្ថ កតមោ ឧបបត្តិភវោ ។ កាមភវោ រូបភវោ អរូប-ភវោ សញ្ញាភវោ អសញ្ញាភវោ នេវសញ្ញានាសញ្ញាភវោ ឯកវោការភវោ ចតុវោការភវោ បញ្ចវោការភវោ អយំ វុច្ចតិ ឧបបត្តិភវោ ។ ឥតិ អយញ្ច កម្មភវោ អយញ្ច ឧបបត្តិភវោ អយំ វុច្ចតិ ឧបាទានប្បច្ចយា ភវោ ។

(១២) តត្ថ កតមា ភវប្បច្ចយា ជាតិ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភវប្បច្ចយា ជាតិ ។

(១៣) តត្ថ កតមំ ជាតិប្បច្ចយា ជរាមរណំ ។ អត្ថិ ជរា អត្ថិ មរណំ ។ តត្ថ កតមា ជរា ។

បណ្ដាភពទាំងនោះ ឧបបត្តិភព តើដូចម្ដេច ។ កាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការ[១]ភព ចតុវោការ[២]ភព បញ្ចវោការ[៣]ភព នេះហៅថា ឧបបត្តិភព ។ កម្មភពនេះផង ឧបបត្តិភពនេះផង នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ដោយប្រការដូច្នេះ ។

( ១២ ) បណ្ដាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្ដេច ។ ការកើត ការកើតព្រម ការចាប់កំណើត ការកើតបំពោះ ការកើតប្រាកដនៃខន្ធទាំងឡាយ ការបានចំពោះនូវអាយតនៈទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

(១៣) បណ្ដាបច្ចយាការទាំងនោះ ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្ដេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្ដាជរានិងមរណៈ

---

១ ភពមានខន្ធ ១ គឺអសញ្ញិភព ។ ២ ភពនោះមានខន្ធ ៤ គឺអរូបភព ។ ៣ ភពមានខន្ធ ៥ គឺភពដ៏សេសក្រៅអំពីភព ២ ប្រការនេះ ។ អដ្ឋកថា ( ព្រះសូត្រ ) ។

យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ជរា ។ តត្ថ កតមំ មរណំ ។ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ជាតិប្បច្ចយា ជរាមរណំ ។

(១៤) តត្ថ កតមោ សោកោ ។ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ ចេតសោ បរិជ្ឈាយនា ទោមនស្សំ សោកសល្លំ អយំ វុច្ចតិ សោកោ ។

នោះ ជរា តើដូចម្តេច ។ សេចក្តីចាស់គ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ ការរួញថយនៃអាយុ ការចាស់ទុំនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះ ៗ ក្នុងសត្តនិកាយនោះ ៗ នេះហៅថា ជរា ។ បណ្តាជរានិងមរណៈនោះ មរណៈ តើដូចម្តេច ។ ការច្យុតិ ការឃ្លាត ការបែកធ្លាយ ការបាត់បង់ មច្ចុ មរណៈ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិល នូវជីវិតិន្ទ្រិយ ណា ចាកសត្តនិកាយនោះ ៗ របស់សត្វទាំងឡាយ នោះៗ នេះហៅថា មរណៈ ។ ជរានេះឯង មរណៈនេះឯង នេះហៅថា ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

(១៤) បណ្តាបច្ចយាការទាំងនោះ សោកៈ តើដូចម្តេច ។ សេចក្តីសោក អាការសោក ភាពនៃសេចក្តីសោក ការស្ងួតស្ងប់ខាងក្នុង ការក្រៀមក្រំខាងក្នុង ការជ្រប់ស្រពោននៃចិត្ត ការតូចចិត្ត សរគឺសេចក្តីសោក របស់បុគ្គលដែលត្រូវសេចក្តីវិនាសញាតិ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសភោគៈ ប៉ះពាល់ក្តី ត្រូវសេចក្តីវិនាស គឺរោគប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសសីលប៉ះពាល់ក្តី ត្រូវសេចក្តីវិនាសគឺទិដ្ឋិប៉ះពាល់ក្តី ឬប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា សោកៈ ។

## បច្ចយាការវិភង្គេ សុត្តន្តភាជនីយំ

(១៥) តត្ថ កតមោ បរិទេវោ ។ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ វាចា បលាបោ វិប្ប-លាបោ លាលបោ លាលបនា លាលបិតត្តំ អយំ វុច្ចតិ បរិទេវោ ។

(១៦) តត្ថ កតមំ ទុក្ខំ ។ យំ កាយិកំ អសាតំ កាយិកំ ទុក្ខំ កាយសម្ផស្សជំ អសាតំ វេទយិតំ កាយសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទុក្ខំ ។

(១៧) តត្ថ កតមំ ទោមនស្សំ ។ យំ ចេត-សិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។

បច្ចយាការវិភង្គ សុត្តន្តភាជនីយ

(១៥) បណ្ដាបច្ចយាការទាំងនោះ បរិទេវៈ តើដូចម្ដេច ។ សេចក្ដីខ្សឹកខ្សួល ការទួញយំ អាការខ្សឹកខ្សួល អាការទួញយំ ភាពខ្សឹកខ្សួល ភាពទួញយំ ការពោល ការយំរៀបរាប់ ការយំអណ្ដឺតអណ្ដក ការពោលដែល ៗ អាការពោលដែល ៗ ភាពពោលដដែល ៗ របស់បុគ្គលដែលត្រូវសេចក្ដីវិនាសញាតិ ប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសភោគៈប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺរោគប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសសីលប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺទិដ្ឋិប៉ះពាល់ក្ដី ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយប៉ះពាល់ហើយ នេះហៅថា បរិទេវៈ ។

(១៦) បណ្ដាបច្ចយាការទាំងនោះ ទុក្ខៈ តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនជាទីត្រេកអរ ដែលកើតអំពីកាយសម្ផស្ស វេទនា មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីកាយសម្ផស្ស ណា នេះហៅថា ទុក្ខៈ ។

(១៧) បណ្ដាបច្ចយាការទាំងនោះ ទោមនស្សៈ តើដូចម្ដេច ។ សេចក្ដីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស វេទនាមិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្សណា នេះហៅថា ទោមនស្ស ។

(១៨) តត្ថ កតមោ ឧបាយាសោ ។ ញាតិព្យសនេន វា ផុដ្ឋស្ស ភោគព្យសនេន វា ផុដ្ឋស្ស រោគព្យសនេន វា ផុដ្ឋស្ស សីលព្យសនេន វា ផុដ្ឋស្ស ទិដ្ឋិព្យសនេន វា ផុដ្ឋស្ស អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ ឧបាយាសោ ។

(១៩) ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សង្គតិ ហោតិ សមាគមោ ហោតិ សមោធានំ ហោតិ បាតុភាវោ ហោតិ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

## សុត្តន្តភាជនីយំ ។

(២០) អវិជ្ជាបច្ចយា សង្ខារា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមំ នាមបច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនបច្ចយា ផស្សោ ផស្សបច្ចយា

(១៨) បណ្ដាបច្ច័យាការទាំងនោះ ឧបាយាសៈ តើដូចម្ដេច ។ សេចក្ដីតានតឹងចិត្ត ភាពតានតឹងចិត្ត ភាពចង្អៀតចង្អល់ចិត្ត របស់បុគ្គលដែលត្រូវសេចក្ដីវិនាសញាតិប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសភោគៈប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺរោគប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសសីលប៉ះពាល់ក្ដី ត្រូវសេចក្ដីវិនាសគឺទិដ្ឋិប៉ះពាល់ក្ដី ឬប្រកបដោយសេចក្ដីវិនាសណាមួយ ឬក៏ត្រូវទុក្ខធម៌ណាមួយ ប៉ះពាល់ហើយ នេះហៅថា ឧបាយាសៈ ។

(១៩) ត្រង់ពាក្យថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុះ រមែងមាន ដោយអាការយ៉ាងនេះ គឺការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃកងទុក្ខទាំងអស់នុះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

ចប់ សុត្តន្តភាជនីយ ។

(២០) សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជា

វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២១) អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមំ នាមបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេ-តស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២២) អវិជ្ជាបច្ចយា សង្ខារោ សង្ខារ-បច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា

បច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៦១) សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៦២) សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ

តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២៣) អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូប-បច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវ-មេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

## បច្ចយចតុក្កំ ។

(២៤) អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ សង្ខារបច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញា-ណបច្ចយា នាមំ វិញ្ញាណហេតុកំ នាមបច្ចយា ឆដ្ឋាយតនំ នាមហេតុកំ ឆដ្ឋាយតនបច្ចយា

តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៦៣] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ បច្ចយវគ្គៈ ។

[៦៤] សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ មានអាយតនៈទី ៦

ផស្សោ ឆដ្ឋាយតនហេតុកោ ផស្សបច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុកា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(២៥) អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ សង្ខារបច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណបច្ចយា នាមំ វិញ្ញាណហេតុកំ នាមបច្ចយា ផស្សោ នាមហេតុកោ ផស្សបច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុកា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ២៥ ] សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណមានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមមានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈមាននាម ជាហេតុ កើតមាន ព្រោះនាមជាបច្ច័យ វេទនាមានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាមានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[២៦] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ
សង្ខារបច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណប-
ច្ចយា នាមរូបំ វិញ្ញាណហេតុកំ នាមរូបបច្ចយា
ឆដ្ឋាយតនំ នាមរូបហេតុកំ ឆដ្ឋាយតនបច្ចយា
ផស្សោ ឆដ្ឋាយតនហេតុកោ ផស្សបច្ចយា វេទនា
ផស្សហេតុកា វេទនាបច្ចយា តណ្ហា វេទនាហេតុ-
កា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបា-
ទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិប-
ច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខ-
ន្ធស្ស សមុទយោ ហោតិ ។

[២៧] អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាហេតុកោ
សង្ខារបច្ចយា វិញ្ញាណំ សង្ខារហេតុកំ វិញ្ញាណ-
បច្ចយា នាមរូបំ វិញ្ញាណហេតុកំ នាមរូប-
បច្ចយា សឡាយតនំ នាមរូបហេតុកំ សឡាយ-
តនបច្ចយា ផស្សោ សឡាយតនហេតុកោ ផស្ស-
បច្ចយា វេទនា ផស្សហេតុកា វេទនាបច្ចយា

(៦៦) សង្ខារមានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ មាននាមនិងរូបជាហេតុ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ មានអាយតនៈទី ៦ ជាហេតុ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៦៧) សង្ខារ មានអវិជ្ជាជាហេតុ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ មានសង្ខារជាហេតុ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប មានវិញ្ញាណជាហេតុ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ មាននាមនិងរូបជាហេតុ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ មានអាយតនៈ ៦ ជាហេតុ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា មានផស្សៈជាហេតុ កើតមាន ព្រោះផស្សៈជាបច្ច័យ

តណ្ហា វេទនាហេតុកា តណ្ហាបច្ចយា ឧបាទានំ តណ្ហាហេតុកំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

## ហេតុចតុក្កំ ។

[២៨] អវិជ្ជាបច្ចយា សង្ខារា អវិជ្ជាសម្បយុត្តា សង្ខារបច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណបច្ចយា នាមំ វិញ្ញាណសម្បយុត្តំ នាមបច្ចយា ឆដ្ឋាយតនំ នាមសម្បយុត្តំ ឆដ្ឋាយតនបច្ចយា ផស្សោ ឆដ្ឋាយតនសម្បយុត្តោ ផស្សបច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

តណ្ហា មានវេទនាជាហេតុ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន មានតណ្ហាជាហេតុ កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ ហេតុបតុក្កៈ ។

(២៨) សង្ខារ ប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមានព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ។

(២៩) អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តា សង្ខារបច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណបច្ចយា នាមំ វិញ្ញាណសម្បយុត្តំ នាមបច្ចយា ផស្សោ នាមសម្បយុត្តោ ផស្សបច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៣០) អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តា សង្ខារបច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណបច្ចយា នាមរូបំ វិញ្ញាណសម្បយុត្តំ នាមរូបបច្ចយា ឆដ្ឋាយតនំ នាមរូបសម្បយុត្តំ ឆដ្ឋាយតនបច្ចយា ផស្សោ ឆដ្ឋាយតនសម្បយុត្តោ ផស្សបច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានបច្ចយា ភវោ ភវបច្ចយា

(២៩) សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្ស ប្រកបដោយនាម កើតមាន ព្រោះនាមជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៣០) សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូបប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ ប្រកបដោយនាមនិងរូប កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈទី ៦ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ

ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៣១) អវិជ្ជាបច្ចយា សង្ខារោ អវិជ្ជាសម្បយុត្តោ សង្ខារបច្ចយា វិញ្ញាណំ សង្ខារសម្បយុត្តំ វិញ្ញាណបច្ចយា នាមរូបំ វិញ្ញាណសម្បយុត្តំ នាមំ នាមរូបបច្ចយា សឡាយតនំ នាមសម្បយុត្តំ សឡាយតនបច្ចយា ផស្សោ សឡាយតនសម្បយុត្តោ ផស្សបច្ចយា វេទនា ផស្សសម្បយុត្តា វេទនាបច្ចយា តណ្ហា វេទនាសម្បយុត្តា តណ្ហាបច្ចយា ឧបាទានំ តណ្ហាសម្បយុត្តំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

## សម្បយុត្តចតុក្កំ ។

(៣២) អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយាបិ អវិជ្ជា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយាបិ សង្ខារោ វិញ្ញាណបច្ចយា នាមំ នាមបច្ចយាបិ

ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[ ៣១ ] សង្ខារប្រកបដោយអវិជ្ជា កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណប្រកបដោយសង្ខារ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូបប្រកបដោយវិញ្ញាណ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាមនិងអាយតនៈ៦ ប្រកបដោយនាម កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈប្រកបដោយអាយតនៈ៦ កើតមាន ព្រោះអាយតនៈ៦ ជាបច្ច័យ វេទនា ប្រកបដោយផស្សៈ កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហាប្រកបដោយវេទនា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានប្រកបដោយតណ្ហា កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ សម្បយុត្តចតុក្ក ។

[ ៣២ ] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ

វិញ្ញាណំ នាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយាបិ នាមំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយាបិ ឆដ្ឋាយតនំ ផស្សប្បច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៣៣) អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយាបិ អវិជ្ជា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយាបិ សង្ខារោ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយាបិ វិញ្ញាណំ នាមប្បច្ចយា ផស្សោ ផស្សប្បច្ចយាបិ នាមំ ផស្សប្បច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ

វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៣៣] សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ នាម កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន

ឧបាទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៣៤) អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយាបិ អវិជ្ជា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយាបិ សង្ខារោ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយាបិ វិញ្ញាណំ នាមរូបប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយាបិ នាមរូបំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយាបិ ឆដ្ឋាយតនំ ផស្សប្បច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយាបិ តណ្ហា ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៣៤) សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ នាមនិងរូបកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនា កើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៣៥) អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយាបិ អវិជ្ជា សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយាបិ សង្ខារោ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយាបិ វិញ្ញាណំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយាបិ នាមរូបំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយាបិ សឡាយតនំ ផស្សបច្ចយា វេទនា វេទនាបច្ចយាបិ ផស្សោ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយាបិ វេទនា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយាបិ តណ្ហា ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

អញ្ញមញ្ញចតុក្កំ ។

(៣៦) សង្ខារបច្ចយា អវិជ្ជា ។ បេ ។ វិញ្ញាណបច្ចយា អវិជ្ជា ។ បេ ។ នាមបច្ចយា អវិជ្ជា ។ បេ ។ ឆដ្ឋាយតនបច្ចយា អវិជ្ជា ។ បេ ។

(៣៥) សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ សង្ខារ កើតមាន ព្រោះវិញ្ញាណជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ អាយតនៈ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ នាមនិងរូប កើតមាន ព្រោះអាយតនៈ៦ជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ៦ជាបច្ច័យ អាយតនៈ៦ កើតមាន ព្រោះផស្សៈជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ផស្សៈ កើតមាន ព្រោះវេទនាជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ វេទនាកើតមាន ព្រោះតណ្ហាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តណ្ហា កើតមាន ព្រោះឧបាទានជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ អញ្ញមញ្ញចតុក្កៈ ។

(៣៦) អវិជ្ជា កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះនាមជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះអាយតនៈ៦ជាបច្ច័យ ។ បេ ។

ផស្សប្បច្ចយា អវិជ្ជា ។ បេ ។ វេទនាបច្ចយា អវិជ្ជា ។ បេ ។ តណ្ហាបច្ចយា អវិជ្ជា ។ បេ ។ ឧបាទានប្បច្ចយា អវិជ្ជា ។ បេ ។ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

មាតិកា ។

(៣៧) កតមេ ធម្មា អកុសលា ។ យស្មឹ សមយេ អកុសលំ ចិត្តំ ឧប្បន្នំ ហោតិ សោមនស្សសហគតំ ទិដ្ឋិគតសម្បយុត្តំ រូបារម្មណំ វា សទ្ទារម្មណំ វា គន្ធារម្មណំ វា រសារម្មណំ វា ផោដ្ឋព្វារម្មណំ វា ធម្មារម្មណំ វា យំ យំ វា បនារព្ភ តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា

អវិជ្ជា កើតមាន ព្រោះផស្សៈជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះវេទនាជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះតណ្ហាជាបច្ច័យ ។ បេ ។ អវិជ្ជា កើតមាន ព្រោះឧបាទានជាបច្ច័យ ។ បេ ។ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

ចប់ មាតិកា ។

(៣៧) ធម៌ទាំងឡាយ ជាអកុសល តើដូចម្តេច ។ ក្នុងសម័យណា អកុសលចិត្ត ដែលប្រកបដោយសោមនស្ស ប្រកបដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសម្លេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផ្សព្វជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ

នាមំ នាមបច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៣៨) តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។បេ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។

(៣៩) តត្ថ កតមេ អវិជ្ជាបច្ចយា សង្ខារា ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារា ។

(៤០) តត្ថ កតមំ សង្ខារបច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារបច្ចយា វិញ្ញាណំ ។

នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៣៨) បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង មិនឃើញ ។បេ។ គន្លឹះគឺអវិជ្ជា មោហៈជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។

(៣៩) បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

(៤០) បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហទយៈ ធម្មជាតដ៏ផូរផង់ (គឺភវង្គចិត្ត) ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

## បច្ចយាការវិភង្គោ អកុសលនិទ្ទេសោ

(៤១) តត្ថ កតមំ វិញ្ញាណបច្ចយា នាមំ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ វិញ្ញាណបច្ចយា នាមំ ។

(៤២) តត្ថ កតមំ នាមបច្ចយា ឆដ្ឋាយតនំ ។ យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ នាមបច្ចយា ឆដ្ឋាយតនំ ។

(៤៣) តត្ថ កតមោ ឆដ្ឋាយតនបច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ឆដ្ឋាយតនបច្ចយា ផស្សោ ។

(៤៤) តត្ថ កតមា ផស្សបច្ចយា វេទនា ។ យំ ចេតសិកំ សាតំ ចេតសិកំ សុខំ ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ ចេតោសម្ផស្សជា សាតា សុខា វេទនា អយំ វុច្ចតិ ផស្សបច្ចយា វេទនា ។

(៥១) បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

(៥២) បណ្ដាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហទយៈ ធម្មជាតដ៏ផូរផង់ (គឺភវង្គចិត្ត) ហៅថា មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។

(៥៣) បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិច ណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

(៥៤) បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសារ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសារ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស វេទនា ដ៏ឆ្ងាញ់ពិសារ ជាសុខ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ ។

(២៥) តត្ថ កតមា វេទនាបច្ចយា តណ្ហា ។ យោ រាគោ សារាគោ អនុនយោ អនុរោធោ នន្ទី នន្ទិរាគោ ចិត្តស្ស សារាគោ អយំ វុច្ចតិ វេទនាបច្ចយា តណ្ហា ។

(២៦) តត្ថ កតមំ តណ្ហាបច្ចយា ឧបាទានំ ។ យា ទិដ្ឋិ ទិដ្ឋិគតំ ។ បេ ។ តិត្ថាយតនំ វិបរិយេសគ្គាហោ ឥទំ វុច្ចតិ តណ្ហាបច្ចយា ឧបាទានំ ។

(២៧) តត្ថ កតមោ ឧបាទានបច្ចយា ភវោ ។ ឋបេត្វា ឧបាទានំ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ អយំ វុច្ចតិ ឧបាទានបច្ចយា ភវោ ។

(២៨) តត្ថ កតមា ភវបច្ចយា ជាតិ ។ យា តេសំ ធម្មានំ ជាតិ សញ្ជាតិ និព្វត្តិ អភិនិព្វត្តិ បាតុភាវោ អយំ វុច្ចតិ ភវបច្ចយា ជាតិ ។

(៤៥) បណ្ដាបច្ចយាការទាំងនោះ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ តម្រេក តម្រេកខ្លាំង ការត្រេកអរ ការក្ដួចកាន់ ការរីករាយ ការស្រើបស្រាល តម្រេកដ៏ខ្លាំង ណា នៃចិត្ត នេះហៅថា តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ។

(៤៦) បណ្ដាបច្ចយាការទាំងនោះ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ លទ្ធិដូចជាកំពង់គឺទិដ្ឋិ ការប្រកាន់ក្ដង់ការស្វែងរកខុស ណា នេះហៅថា ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ។

(៤៧) បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ វៀរលែងតែឧបាទានចេញ នេះហៅថា ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ។

(៤៨) បណ្ដាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្ដេច ។ ការកើត ការកើតព្រម ការផ្ដួចឡើង ការកើតចំពោះ ការកើតប្រាកដ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

បច្ចយាការវិភង្គ អកុសលនិទ្ទេស

(៤៩) តត្ថ កតមំ ជាតិប្បច្ចយា ជរាមរណំ ។ អត្ថិ ជរា អត្ថិ មរណំ ។ តត្ថ កតមា ជរា ។ យា តេសំ ធម្មានំ ជរា ជីរណតា អាយុនោ សំហានិ អយំ វុច្ចតិ ជរា ។ តត្ថ កតមំ មរណំ ។ យោ តេសំ ធម្មានំ ខយោ វយោ ភេទោ បរិភេទោ អនិច្ចតា អន្តរធានំ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ជាតិប្បច្ចយា ជរាមរណំ ។

(៥០) ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សង្គតិ ហោតិ សមាគមោ ហោតិ សមោធានំ ហោតិ បាតុភាវោ ហោតិ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

(៥១) តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា

បច្ចយាការវិភង្គ អកុសលនិទ្ទេស

(៤៩) បណ្ដាបច្ចយាការទាំងនោះ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្ដេច ។ ជរាក៏មាន មរណៈក៏មាន ។ បណ្ដាជរានិងមណៈនោះ ជរា តើដូចម្ដេច ។ ការចាស់គ្រាំគ្រា ការរួញថយទៅនៃអាយុ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា ជរា ។ បណ្ដាជរានិងមរណៈនោះ មរណៈតើដូចម្ដេច ។ ការអស់ទៅ ការសូន្យទៅ ការបែកធ្លាយ ការបែកខ្ចាត់ខ្ចាយ ការមិនទៀង ការបាត់បង់ ណា នៃធម៌ទាំងឡាយនោះ នេះហៅថា មរណៈ ។ ជរានេះផង មរណៈនេះផង នេះហៅថា ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

(៥០) ត្រង់ពាក្យថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ គឺការជួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបលោកពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៥១) ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ

តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវ-
បច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស
កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៤២) តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ
អទស្សនំ ។បេ។ អវិជ្ជាលង្គី មោហោ អកុសល-
មូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមោ អវិ-
ជ្ជាបច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា
សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខា-
រោ ។ តត្ថ កតមំ សង្ខារបច្ចយា វិញ្ញាណំ ។
យំ ចិត្តំ មនោ មានសំ ។បេ។ តជ្ជា មនោវិញ្ញា-
ណធាតុ ឥទំ វុច្ចតិ សង្ខារបច្ចយា វិញ្ញាណំ ។ តត្ថ
កតមំ វិញ្ញាណបច្ចយា នាមំ ។ វេទនាក្ខន្ធោ
សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ វិញ្ញាណបច្-
ចយា នាមំ ។ នាមបច្ចយា ផស្សោតិ តត្ថ កតមំ
នាមំ ។ ឋបេត្វា ផស្សំ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ
សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។

ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

[៤២] បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លុះ គឺអវិជ្ជា មោហៈ ជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។ អធិប្បាយត្រង់ពាក្យថា ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ ។ ចុះបណ្ដាធម៌ទាំងនោះ នាម តើដូចម្ដេច ។

តត្ថ កតមោ នាមបច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ នាមបច្ចយា ផស្សោ ។បេ។ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

(៥៣) តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៥៤) តត្ថ កតមា អវិជ្ជា ។ អយំ អញ្ញាណំ អទស្សនំ ។បេ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ

វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកលែងតែផស្សៈចេញ នេះហៅថា នាម ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ផស្សៈការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិច ណា នេះហៅថា ផស្សៈកើតមាន ព្រោះនាមជាបច្ច័យ ។ បេ ។ ព្រោះហេតុនោះ ទើបលោកហៅថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៤៣) ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៤៤) បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លឹះគឺអវិជ្ជា មោហៈ ជាអកុសលមូល

អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមេ អវិជ្ជាបច្ចយា សង្ខា-
រោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ
វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ ។ តត្ថ កតមំ សង្ខារបច្-
ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ។បេ។ តជ្ជា
មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារបច្ចយា វិញ្ញា-
ណំ ។ តត្ថ កតមំ វិញ្ញាណបច្ចយា នាមរូបំ ។ អត្ថិ
នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាក្ខន្ធោ
សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ
កតមំ រូបំ ។ ចក្ខាយតនស្ស ឧបចយោ សោ-
តាយតនស្ស ឧបចយោ ឃានាយតនស្ស ឧបច-
យោ ជិវ្ហាយតនស្ស ឧបចយោ កាយាយតនស្ស
ឧបចយោ យំ វា បនញ្ញម្បិ អត្ថិ រូបំ ចិត្តជំ ចិត្ត-
ហេតុកំ ចិត្តសមុដ្ឋានំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច
នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ វិញ្ញាណបច្ចយា
នាមរូបំ ។ នាមរូបបច្ចយា ឆដ្ឋាយតនន្តិ អត្ថិ នាមំ

ណា នេះហៅថា អវិជ្ជា ៗ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ៗ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ៗ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ៗ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ៗ បេ ៗ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ៗ បណ្ដាបច្ចយាការទាំងនោះ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ៗ នាមក៏មាន រូបក៏មាន ៗ បណ្ដានាមនិងរូបទាំងនោះ នាម តើដូចម្ដេច ៗ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ៗ បណ្ដានាមនិងរូបទាំងនោះ រូប តើដូចម្ដេច ៗ ការសន្សំនៃចក្ខាយតនៈ ការសន្សំនៃសោតាយតនៈ ការសន្សំនៃឃា-នាយតនៈ ការសន្សំនៃជិវ្ហាយតនៈ ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ៗ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ៗ អធិប្បាយត្រង់ពាក្យថា អាយតនៈទី៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ នាមក៏មាន

អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ យំ រូបំ និស្សាយ មនោវិញ្ញាណធាតុ វត្តតិ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ នាមរូបំ ។ តត្ថ កតមំ នាមរូបបច្ចយា ឆដ្ឋាយតនំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ នាមរូបបច្ចយា ឆដ្ឋាយតនំ ។ តត្ថ កតមោ ឆដ្ឋាយតនបច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ឆដ្ឋាយតនបច្ចយា ផស្សោ ។ បេ ។ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

(៥៥) តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ សង្ខារបច្ចយា វិញ្ញាណំ វិញ្ញាណបច្ចយា នាមរូបំ នាមរូបបច្ចយា សឡាយតនំ សឡាយតនបច្ចយា ផស្សោ ផស្សបច្ចយា វេទនា វេទនាបច្ចយា តណ្ហា

រូបក៏មាន ។ បណ្ដានាម និង រូបនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាមនិងរូបនោះ រូប តើដូចម្ដេច ។ មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណា នេះហៅថា រូប ។ នាមនេះឯង រូបនេះឯង នេះហៅថា នាមនិងរូប ។ បណ្ដាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ តើដូចម្ដេច ។ ចិត្ដៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គុកទង្គិប ណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ ។បេ។ ព្រោះហេតុនោះ ទើបលោកថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៥៥) ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈ ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ តណ្ហា កើតមាន ព្រោះវេទនាជាបច្ច័យ

តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(៤៦) តត្ថ កតមា អវិជ្ជា ។ យំ អញ្ញាណំ អទស្សនំ ។បេ។ អវិជ្ជាលង្គី មោហោ អកុសលមូលំ អយំ វុច្ចតិ អវិជ្ជា ។ តត្ថ កតមោ អវិជ្ជាបច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អវិជ្ជាបច្ចយា សង្ខារោ ។ តត្ថ កតមំ សង្ខារបច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ។បេ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារបច្ចយា វិញ្ញាណំ ។ តត្ថ កតមំ វិញ្ញាណបច្ចយា នាមរូបំ ។ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ ចក្ខាយតនស្ស ឧបចយោ ។បេ។

ឧបាទាន កើតមាន ព្រោះតណ្ហាជាបច្ច័យ ភព កើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(៥៦) បណ្ដាបច្ចយាការទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។ បេ ។ គន្លឹះគឺអវិជ្ជា មោហៈ ជាអកុសលមូល ណា នេះហៅថា អវិជ្ជា ។ បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្តៈ សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។ បណ្ដាបច្ចយាការទាំងនោះ នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ នាមក៏មាន រូបក៏មាន ។ បណ្ដានាមនិងរូបទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្ដានាមនិងរូបទាំងនោះ រូប តើដូចម្ដេច ។ ការសន្សំនៃចក្ខាយតនៈ ។ បេ ។

កាយាយតនស្ស ឧបចយោ យំ វា បនញ្ញម្បិ អត្ថិ រូបំ ចិត្តជំ ចិត្តហេតុកំ ចិត្តសមុដ្ឋានំ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ វិញ្ញាណបច្ចយា នាមរូបំ ។ នាមរូបបច្ចយា សឡាយតនន្តិ អត្ថិ នាមំ អត្ថិ រូបំ ។ តត្ថ កតមំ នាមំ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ នាមំ ។ តត្ថ កតមំ រូបំ ។ ចត្តារោ ច មហាភូតា យញ្ច រូបំ និស្សាយ មនោវិញ្ញាណធាតុ វត្តតិ ឥទំ វុច្ចតិ រូបំ ។ ឥតិ ឥទញ្ច នាមំ ឥទញ្ច រូបំ ឥទំ វុច្ចតិ នាមរូបំ ។ តត្ថ កតមំ នាមរូបបច្ចយា សឡាយតនំ ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ឥទំ វុច្ចតិ នាមរូបបច្ចយា សឡាយតនំ ។ តត្ថ កតមោ សឡាយតនបច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ សឡាយតនបច្ចយា ផស្សោ ។ បេ ។

ការសន្សំនៃកាយាយតនៈ ឬក៏រូបដទៃណា ដែលកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ដោយប្រការដូច្នេះ ។ អធិប្បាយត្រង់ពាក្យថា អាយតនៈ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ នាមក៏មាន រូបក៏មាន ។ បណ្តានាមនិងរូបនោះ នាម តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម ។ បណ្តានាមនិងរូបទាំងនោះ រូប តើដូចម្តេច ។ មហាភូតរូបទាំង៤ក្តី មនោវិញ្ញាណធាតុ ប្រព្រឹត្តទៅ ព្រោះអាស្រ័យនូវរូបណាក្តី នេះហៅថា រូប ។ នាមនេះផង រូបនេះផង នេះហៅថា នាមនិងរូប ដោយប្រការដូច្នេះ ។ បណ្តាបច្ចយាការទាំងនោះ អាយតនៈ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ តើដូចម្តេច ។ ចក្ខាយតនៈ១ សោតាយតនៈ១ ឃានាយតនៈ១ ជិវ្ហាយតនៈ១ កាយាយតនៈ១ មនាយតនៈ១ នេះហៅថា អាយតនៈ៦ កើតមាន ព្រោះនាមនិងរូបជាបច្ច័យ ។ បណ្តាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះសឡាយតនៈជាបច្ច័យ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្កិកទង្គិច ណា នេះហៅថា ផស្សៈ កើតមាន ព្រោះ អាយតនៈ៦ ជាបច្ច័យ ។ បេ ។

តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

បច្ចយចតុក្កំ ។

(១៦៣) បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ ។ បេ ។ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(១៦៤) ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា សោតវិញ្ញាណ ជាវិបាក ប្រកបដោយទុក្ខ មានសម្លេងជាអារម្មណ៍ កើតឡើង ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ។ បេ ។ ឃានវិញ្ញាណ ប្រកបដោយទុក្ខ មានក្លិនជាអារម្មណ៍ កើតឡើង ។ បេ ។ ជិវ្ហាវិញ្ញាណ ប្រកបដោយទុក្ខ មានរសជាអារម្មណ៍ កើតឡើង ។ បេ ។ កាយវិញ្ញាណ ប្រកបដោយទុក្ខ មានផ្សព្វជាអារម្មណ៍ កើតឡើង ។ បេ ។ មនោធាតុ ប្រកបដោយទុក្ខ មានរូបជាអារម្មណ៍ក្ដី ។ បេ ។ មានផ្សព្វជាអារម្មណ៍ក្ដី ឬក៏ ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ

នាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

(១៦៨) កតមេ ធម្មា អព្យាកតា ។ យស្មឹ សមយេ អកុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកា មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ ឧបេក្ខាសហគតា រូបារម្មណា វា ។បេ។ ធម្មារម្មណា វា យំ យំ វា បនារព្ភ តស្មឹ សមយេ អកុសលមូលប្បច្ចយា សង្ខារោ សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមំ នាមប្បច្ចយា ឆដ្ឋាយតនំ ឆដ្ឋាយតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា អធិមោក្ខោ អធិមោក្ខប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។

អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី៦ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(១៦៨) ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ក្នុងសម័យណា មនោវិញ្ញាណធាតុ ជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្ដី ។ បេ ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណា ៗ ហើយកើតឡើង ព្រោះភាពនៃអកុសលកម្ម ដែលសត្វធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ជាតិ កើតមាន ព្រោះភពជាបច្ច័យ ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ។

(១៦៦) តត្ថ កតមោ អកុសលមូលប្បច្ចយា សង្ខារោ ។ យា ចេតនា សញ្ចេតនា សញ្ចេតយិតត្តំ អយំ វុច្ចតិ អកុសលមូលប្បច្ចយា សង្ខារោ ។

(១៦៧) តត្ថ កតមំ សង្ខារប្បច្ចយា វិញ្ញាណំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ សង្ខារប្បច្ចយា វិញ្ញាណំ ។

(១៦៨) តត្ថ កតមំ វិញ្ញាណប្បច្ចយា នាមំ ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមំ ។

(១៦៩) តត្ថ កតមំ នាមប្បច្ចយា ឆដ្ឋាយតនំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ នាមប្បច្ចយា ឆដ្ឋាយតនំ ។

(១៧០) តត្ថ កតមោ ឆដ្ឋាយតនប្បច្ចយា ផស្សោ ។ យោ ផស្សោ ផុសនា សម្ផុសនា សម្ផុសិតត្តំ អយំ វុច្ចតិ ឆដ្ឋាយតនប្បច្ចយា ផស្សោ ។

[១៦៦] បណ្ដាបច្ចយាការទាំងនោះ សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ តើដូចម្ដេច ។ ចេតនា ការសន្សំ ភាពនៃការសន្សំ (នូវអារម្មណ៍) ណា នេះហៅថា សង្ខារ កើតមាន ព្រោះអកុសលមូលជាបច្ច័យ ។

[១៦៧] បណ្ដាបច្ចយាការទាំងនោះ វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា វិញ្ញាណ កើតមាន ព្រោះសង្ខារជាបច្ច័យ ។

[១៦៨] បណ្ដាបច្ចយាការទាំងនោះ នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះហៅថា នាម កើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

[១៦៩] បណ្ដាបច្ចយាការទាំងនោះ អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ ។

[១៧០] បណ្ដាបច្ចយាការទាំងនោះ ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ តើដូចម្ដេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិតទង្គិច ណា នេះហៅថា ផស្សៈ កើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ ។

( ១៧១ ) តត្ថ កតមា ផស្សប្បច្ចយា វេទនា ។ យំ ចេតសិកំ នេវ សាតំ នាសាតំ ចេតោសម្ផស្សជំ អទុក្ខមសុខំ វេទយិតំ ចេតោសម្ផស្សជា អទុក្ខមសុខា វេទនា អយំ វុច្ចតិ ផស្សប្បច្ចយា វេទនា ។

( ១៧២ ) តត្ថ កតមោ វេទនាបច្ចយា អធិមោក្ខោ ។ យោ ចិត្តស្ស អធិមោក្ខោ អធិមុច្ចនា តទធិមុត្តតា អយំ វុច្ចតិ វេទនាបច្ចយា អធិមោក្ខោ ។

( ១៧៣ ) តត្ថ កតមោ អធិមោក្ខប្បច្ចយា ភវោ ។ ឋបេត្វា អធិមោក្ខំ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ អយំ វុច្ចតិ អធិមោក្ខប្បច្ចយា ភវោ ។

( ១៧៤ ) តត្ថ កតមា ភវប្បច្ចយា ជាតិ ។ យា តេសំ ធម្មានំ ជាតិ សញ្ជាតិ និព្វត្តិ អភិនិព្វត្តិ បាតុភាវោ អយំ វុច្ចតិ ភវប្បច្ចយា ជាតិ ។

( ១៧១ ) បណ្ដាបច្ចយាការទាំងនោះ វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ តើដូចម្ដេច ។ សេចក្ដីត្រេកអរ ក៏មិនមែន សេចក្ដីមិនត្រេកអរ ក៏មិនមែន ដែលប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ដែលកើតអំពីចេតោសម្ផស្ស អទុក្ខមសុខ-វេទនា ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា វេទនា កើតមាន ព្រោះផស្សៈជាបច្ច័យ ។

( ១៧២ ) បណ្ដាធម៌ទាំងនោះ អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ តើដូចម្ដេច ។ ការចុះស៊ប់ អាការចុះស៊ប់ ភាពចុះស៊ប់ នៃចិត្ត ក្នុងអារម្មណ៍នោះ ណា នេះហៅថា អធិមោក្ខ កើតមាន ព្រោះវេទនាជាបច្ច័យ ។

( ១៧៣ ) បណ្ដាបច្ចយាការទាំងនោះ ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ លើកតែអធិមោក្ខចេញ នេះហៅថា ភព កើតមាន ព្រោះអធិមោក្ខជាបច្ច័យ ។

( ១៧៤ ) បណ្ដាបច្ចយាការទាំងនោះ ជាតិ កើតមាន ព្រោះភពជាបច្ច័យ តើដូចម្ដេច ។ ជាតិ ការកើតព្រម ការផ្ដួចឡើង ការកើតចំពោះ ការកើតប្រាកដ ណា នៃធម៌ទាំងនោះ នេះហៅថា ជាតិ កើតមាន ព្រោះភពជាបច្ច័យ ។

(១៧៥) តត្ថ កតមំ ជាតិប្បច្ចយា ជរាមរណំ ។ អត្ថិ ជរា អត្ថិ មរណំ ។ តត្ថ កតមា ជរា ។ យា តេសំ ធម្មានំ ជរា ជីរណតា អាយុនោ សំហានិ អយំ វុច្ចតិ ជរា ។ តត្ថ កតមំ មរណំ ។ យោ តេសំ ធម្មានំ ខយោ វយោ ភេទោ បរិភេទោ អនិច្ចតា អន្តរធានំ ឥទំ វុច្ចតិ មរណំ ។ ឥតិ អយញ្ច ជរា ឥទញ្ច មរណំ ឥទំ វុច្ចតិ ជាតិប្បច្ចយា ជរាមរណំ ។

(១៧៦) ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សង្គតិ ហោតិ សមាគមោ ហោតិ សមោធានំ ហោតិ បាតុភាវោ ហោតិ តេន វុច្ចតិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

អកុសលមូលកវិបាកនិទ្ទេសោ(១) ។

អភិធម្មភាជនីយំ(២) ។

បច្ចយាការវិភង្គោ សមត្តោ(៣) ។

---

១ ឱ. អកុសលវិបាកមូលកំ និដ្ឋិតំ ។ ២ ឱ. អភិធម្មភាជនីយំ និដ្ឋិតំ ។ ៣ ឱ. សមត្តោ បឋមោ ។

[ ១៧៥ ] បណ្ដាបច្ចយាការទាំងនោះ ជរាមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ តើដូចម្ដេច ។ ជរា ក៏មាន មរណៈ ក៏មាន ។ បណ្ដាជរានិងមរណៈនោះ ជរា តើដូចម្ដេច ។ ការចាស់ ការគ្រាំគ្រា ការជ្រួញថយអាយុ ណា នៃធម៌ទាំងនោះ នេះហៅថា ជរា ។ បណ្ដាជរានិងមរណៈនោះ មរណៈ តើដូចម្ដេច ។ ការអស់ ការសូន្យ ការបែកធ្លាយ ការបែកខ្ចាត់ខ្ចាយ ការមិនទៀង ការបាត់បង់ ណា នៃធម៌ទាំងនោះ នេះហៅថា មរណៈ ។ ជរានេះផង មរណៈនេះផង នេះហៅថា ជរានិងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះ ។

[ ១៧៦ ] សេចក្ដីត្រង់ពាក្យថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ដូចតទៅនេះ ។ ការបួបជុំ ការមូលមក ការប្រជុំចុះ ការកើតប្រាកដ នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះ ព្រោះហេតុនោះ ទើបពោលថា ហេតុជាទីកើតឡើង នៃកងទុក្ខទាំងអស់នុ៎ះ រមែងមាន ដោយអាការយ៉ាងនេះឯង ។

ចប់ អកុសលមូលកវិបាកនិទ្ទេស ។

ចប់ អភិធម្មភាជនីយ ។

ចប់ បច្ចយាការវិភង្គ ។

# សតិប្បដ្ឋានវិភង្គោ

( ១៧៧ ) ចត្តារោ សតិប្បដ្ឋានា ឥធ ភិក្ខុ
អជ្ឈត្តំ កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា
កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា
កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ
សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។
អជ្ឈត្តំ វេទនាសុ វេទនានុបស្សី វិហរតិ ពហិទ្ធា
វេទនាសុ វេទនានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា
វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្ប-
ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោម-
នស្សំ ។ អជ្ឈត្តំ ចិត្តេ ចិត្តានុបស្សី វិហរតិ ពហិទ្ធា
ចិត្តេ ចិត្តានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា ចិត្តេ
ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា
វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អជ្ឈត្តំ
ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា ធម្មេសុ
ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មា-
នុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា
វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

# សតិប្បដ្ឋានវិភង្គ

(១៧៧) សតិប្បដ្ឋាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយខាងក្នុង ពិចារណានូវកាយក្នុងកាយខាងក្រៅ ពិចារណានូវកាយ ក្នុងកាយ ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ ភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយខាងក្នុង ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្រៅ ពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ ភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្តខាងក្នុង ពិចារណានូវចិត្ត ក្នុងចិត្តខាងក្រៅ ពិចារណានូវចិត្ត ក្នុងចិត្ត ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ ភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយខាងក្នុង ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយខាងក្រៅ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។

(១៧៨) កថញ្ច ភិក្ខុ អជ្ឈត្តំ កាយេ កា-
យានុបស្សី វិហរតិ ។ ឥធ ភិក្ខុ អជ្ឈត្តំ កាយំ
ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូ-
រំ នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥម-
ស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ
មំសំ ន្ហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ
កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទ-
រិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ
មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា
មុត្តន្តិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុ-
លីករោតិ ស្វវត្ថិតំ(១) អវត្ថបេតិ សោ តំ និមិត្តំ
អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វវត្ថិតំ(១) អវត្ថ-
បេត្វា ពហិទ្ធា កាយេ ចិត្តំ ឧបសំហរតិ ។

(១៧៩) កថញ្ច ភិក្ខុ ពហិទ្ធា កាយេ កាយានុ-
បស្សី វិហរតិ ។ ឥធ ភិក្ខុ ពហិទ្ធា កាយំ ឧទ្ធំ បាទ-
តលា អធោ កេសមត្ថកា តចបរិយន្តំ បូរំ នានប្បកា-
រស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិស្ស កាយេ កេសា

---

១ ឱ. ម. ស្វាវត្ថិតំ ។

[១៧៨] ចុះភិក្ខុ ពិចារណានូវកាយ ក្នុងកាយខាងក្នុង តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយខាងក្នុង (កាយរបស់ខ្លួន) គឺ ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះមាន សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់ចុះនូវកាយ ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់នូវកាយ ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមក នូវចិត្តក្នុងកាយខាងក្រៅ ។

[១៧៩] ចុះភិក្ខុ ពិចារណានូវកាយក្នុងកាយ ខាងក្រៅ តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយខាងក្រៅ (កាយរបស់គេ) គឺ ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយរបស់បុគ្គលនោះមាន សក់

លោមា នខា ទន្តា តចោ មំសំ ន្ហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាវត្ថិតំ វវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វាវត្ថិតំ វវត្ថបេត្វា អជ្ឈត្តពហិទ្ធា កាយេ ចិត្តំ ឧបសំហរតិ ។

(១៨០) កថញ្ច ភិក្ខុ អជ្ឈត្តពហិទ្ធា កាយេ កាយានុបស្សី វិហរតិ ។ ឥធ ភិក្ខុ អជ្ឈត្តពហិទ្ធា កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ ន្ហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ

រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យជានិមិត្ត កំណត់នូវកាយ ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវកាយនោះឲ្យនិមិត្ត កំណត់នូវកាយ ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្តក្នុងកាយ ខាងក្នុងទាំងខាងក្រៅ ។

( ១៨០ ) ចុះភិក្ខុ ពិចារណានូវកាយ ក្នុងកាយ ខាងក្នុងនិងខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយ ខាងក្នុងនិងខាងក្រៅ (កាយរបស់ខ្លួនទាំងកាយរបស់គេ) គឺ ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយមាន សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត

អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ
លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ
សិង្ឃាណិកា លសិកា មុត្តន្តិ ឥតិ ភិក្ខុ អជ្ឈត្ត-
ពហិទ្ធា កាយេ កាយានុបស្សី វិហរតិ អាតាបី
សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈា-
ទោមនស្សំ ។

(១៨១) អនុបស្សីតិ តត្ថ កតមា អនុបស្ស-
នា ។ យា បញ្ញា បជានានា ។បេ។ អមោ-
ហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ អនុ-
បស្សនា ឥមាយ អនុបស្សនាយ ឧបេតោ ហោតិ
សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ
សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ អនុប-
ស្សីតិ ។

(១៨២) វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ
យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហា-
រតីតិ ។

ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ភិក្ខុ ពិចារណា នូវកាយ ក្នុងកាយ ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

(១៨១) សេចក្តីត្រង់ពាក្យថា ភិក្ខុពិចារណា ។ សំនួរថា ចុះបណ្តាពាក្យទាំងនោះ ការពិចារណា តើដូចម្តេច ។ បញ្ញា ការ-ដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា នេះហៅថា ការពិចារណា ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិតចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយបញ្ញាជាគ្រឿងពិចារណានេះ ព្រោះហេតុនោះ ទើបពោលថា ភិក្ខុពិចារណា ។

(១៨២) ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឲ្យរស់នៅ ត្រាច់ទៅ សម្រាក ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

( ១៨៣ ) អាតាបីតិ តត្ថ កតមំ អាតប្បំ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ ឥទំ វុច្ចតិ អាតប្បំ ឥមិនា អាតប្បេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ អាតាបីតិ ។

( ១៨៤ ) សម្បជានោតិ តត្ថ កតមំ សម្បជញ្ញំ ។ យា បញ្ញា បជានានា ។បេ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សម្បជញ្ញំ ឥមិនា សម្បជញ្ញេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ សម្បជានោតិ ។

( ១៨៥ ) សតិមាតិ តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ ។បេ។ សម្មាសតិ អយំ វុច្ចតិ សតិ

( ១៨៣ ) សេចក្តីត្រង់ពាក្យថា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ៗ សំនួរថា ចុះបណ្តាពាក្យទាំងនោះ សេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស តើដូចម្តេច ៗ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ៗ បេ ៗ សេចក្តីព្យាយាមត្រូវ ណា នេះហៅថា សេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប គៀកកើយ ប្រដិតប្រដី ប្រកបព្រម ដោយព្យាយាមជាគ្រឿងដុតកំដៅកិលេសនេះ ព្រោះហេតុនោះ ទើបពោលថា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ៗ

( ១៨៤ ) សេចក្តីត្រង់ពាក្យថា ជាអ្នកដឹងខ្លួន ៗ សំនួរថា ចុះបណ្តាពាក្យទាំងនោះ ពាក្យថា ការដឹងខ្លួន តើដូចម្តេច ៗ បញ្ញា ការដឹងច្បាស់ ៗ បេ ៗ សេចក្តីមិនវង្វេង ការពិចារណានូវធម៌ ការឃើញត្រូវ ណា នេះហៅថា ការដឹងខ្លួន ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប គៀកកើយ ប្រដិតប្រដី ប្រកបព្រម ដោយការដឹងខ្លួននេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកដឹងខ្លួន ៗ

( ១៨៥ ) សេចក្តីត្រង់ពាក្យថា មានស្មារតី ៗ សំនួរថា ចុះបណ្តាពាក្យទាំងនោះ ពាក្យថា ស្មារតី តើដូចម្តេច ៗ ការរឭក ការនឹកឃើញ ៗ បេ ៗ ការរឭកត្រូវ ណា នេះហៅថា ស្មារតី

ឥមាយ សតិយា ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ សតិមាតិ ។

( ១៨៦ ) វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ តត្ថ កតមោ លោកោ ។ ស្វេវ កាយោ លោកោ បញ្ចបិ ឧបាទានក្ខន្ធា លោកោ អយំ វុច្ចតិ លោកោ ។ តត្ថ កតមា អភិជ្ឈា ។ យោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អភិជ្ឈា ។ តត្ថ កតមំ ទោមនស្សំ ។ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។ ឥតិ អយញ្ច អភិជ្ឈា ឥទញ្ច ទោមនស្សំ ឥមម្ហិ លោកេ វិនីតា ហោន្តិ បដិវិនីតា សន្តា សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។

កាយានុបស្សនានិទ្ទេសោ ។

ភិក្ខុជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយស្មារតីនេះ ព្រោះហេតុនោះ ទើប ពោលថា មានស្មារតី ។

[១៨៦] សេចក្តីត្រង់ពាក្យថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។ សំនួរថា បណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ កាយនោះឯង ឈ្មោះថា លោក ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនេះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំងនៃចិត្ត ណា នេះហៅថា អភិជ្ឈា ។ បណ្តាពាក្យទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា ទោមនស្ស ។ ភិក្ខុ ជាអ្នកខ្ទាន កំចាត់បង់ ស្ងប់រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហីនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ នូវអភិជ្ឈានិងទោមនស្សនេះ ក្នុងលោកនេះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបពោលថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។

ចប់ កាយានុបស្សនានិទ្ទេស ។

( ១៨៧ ) កថញ្ច ភិក្ខុ អជ្ឈត្តំ វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សុខំ វេទនំ វេទយមានោ សុខំ វេទនំ វេទយាមីតិ បជានាតិ ទុក្ខំ វេទនំ វេទយមានោ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ អទុក្ខមសុខំ វេទនំ វេទយមានោ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ សាមិសំ វា សុខំ វេទនំ វេទយមានោ សាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា សុខំ វេទនំ វេទយមានោ និរាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ សាមិសំ វា ទុក្ខំ វេទនំ វេទយមានោ សាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ និរាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ និរាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ ។ សោ តំ

[១៨៧] ចុះភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ
ខាងក្នុង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនា
ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនា ក៏
ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនា
ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា កាលទទួលសុខ-
វេទនា ប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខ-
វេទនា ប្រកបដោយអាមិសៈ កាលទទួលសុខវេទនា មិនប្រកបដោយ
អាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា មិនប្រកប
ដោយអាមិសៈ កាលទទួលទុក្ខវេទនា ប្រកបដោយអាមិសៈក្តី ក៏ដឹង
ច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា ប្រកបដោយអាមិសៈ កាល
ទទួលទុក្ខវេទនា មិនប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញ
ទទួលទុក្ខវេទនា មិនប្រកបដោយអាមិសៈ កាលទទួលអទុក្ខមសុខ-
វេទនាប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខ-
មសុខវេទនា ប្រកបដោយអាមិសៈ កាលទទួលអទុក្ខមសុខវេទនា
មិនប្រកបដោយអាមិសៈក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខ-
មសុខវេទនា មិនប្រកបដោយអាមិសៈ ។ ភិក្ខុនោះ រមែងគប់រក

និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាវត្ថិតំ អវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វាវត្ថិតំ អវត្ថបេត្វា ពហិទ្ធា វេទនាសុ ចិត្តំ ឧបសំហរតិ ។

(១៨៨) កថញ្ច ភិក្ខុ ពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សុខំ វេទនំ វេទយមានំ សុខំ វេទនំ វេទយតីតិ បជានាតិ ទុក្ខំ វេទនំ វេទយមានំ ទុក្ខំ វេទនំ វេទយតីតិ បជានាតិ អទុក្ខមសុខំ វេទនំ វេទយមានំ អទុក្ខមសុខំ វេទនំ វេទយតីតិ បជានាតិ សាមិសំ វា សុខំ វេទនំ វេទយមានំ សាមិសំ សុខំ វេទនំ វេទយតីតិ បជានាតិ និរាមិសំ វា សុខំ វេទនំ វេទយមានំ និរាមិសំ សុខំ វេទនំ វេទយតីតិ បជានាតិ សាមិសំ វា ទុក្ខំ វេទនំ វេទយមានំ សាមិសំ ទុក្ខំ វេទនំ វេទយតីតិ បជានាតិ និរាមិសំ វា ទុក្ខំ វេទនំ វេទយមានំ និរាមិសំ ទុក្ខំ វេទនំ វេទយតីតិ បជានាតិ សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានំ សាមិសំ អទុក្ខមសុខំ វេទនំ វេទយតីតិ

អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះ ឲ្យជានិមិត្ត កំណត់នូវវេទនាដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះ ឲ្យជានិមិត្ត កំណត់នូវវេទនា ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមក នូវចិត្ត ក្នុងវេទនាខាងក្រៅ ។

(១៨៨) ចុះភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវបុគ្គល កាលទទួលសុខវេទនាថា បុគ្គលនេះទទួលសុខវេទនា ដឹងច្បាស់នូវបុគ្គល កាលទទួលទុក្ខវេទនាថា បុគ្គលនេះទទួលទុក្ខវេទនា ដឹងច្បាស់នូវបុគ្គល កាលទទួលអទុក្ខមសុខវេទនាថា បុគ្គលនេះ ទទួលអទុក្ខមសុខវេទនា ដឹងច្បាស់នូវបុគ្គល កាលទទួលសុខវេទនា ប្រកបដោយអាមិសៈក្តី ថា បុគ្គលនេះទទួលសុខវេទនា ប្រកបដោយអាមិសៈ ដឹងច្បាស់នូវបុគ្គល កាលទទួលសុខវេទនា មិនប្រកបដោយអាមិសៈក្តីថា បុគ្គលនេះទទួលសុខវេទនា មិនប្រកបដោយអាមិសៈ ដឹងច្បាស់នូវបុគ្គល កាលទទួលទុក្ខវេទនា ប្រកបដោយអាមិសៈក្តីថា បុគ្គលនេះ ទទួលទុក្ខវេទនា ប្រកបដោយអាមិសៈ ដឹងច្បាស់ នូវបុគ្គល កាលទទួលវេទនា មិនប្រកបដោយអាមិសៈក្តីថា បុគ្គលនេះទទួលទុក្ខវេទនា មិនប្រកបដោយអាមិសៈ ដឹងច្បាស់នូវបុគ្គល កាលទទួលអទុក្ខមសុខវេទនា ប្រ-កបដោយអាមិសៈក្តីថា បុគ្គលនេះ ទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិសៈ ដឹងច្បាស់ នូវបុគ្គល កាលទទួលអទុក្ខមសុខវេទនា

បជានាតិ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានំ និរាមិសំ អទុក្ខមសុខំ វេទនំ វេទយតីតិ បជានាតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាវត្ថិតំ អវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វាវត្ថិតំ អវត្ថបេត្វា អជ្ឈត្តពហិទ្ធា វេទនាសុ ចិត្តំ ឧបសំហរតិ ។

(១៨៩) កថញ្ច ភិក្ខុ អជ្ឈត្តពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សុខំ វេទនំ សុខា វេទនាតិ បជានាតិ ទុក្ខំ វេទនំ ទុក្ខា វេទនាតិ បជានាតិ អទុក្ខមសុខំ វេទនំ អទុក្ខមសុខា វេទនាតិ បជានាតិ សាមិសំ សុខំ វេទនំ សាមិសា សុខា វេទនាតិ បជានាតិ និរាមិសំ សុខំ វេទនំ និរាមិសា សុខា វេទនាតិ បជានាតិ សាមិសំ ទុក្ខំ វេទនំ សាមិសា ទុក្ខា វេទនាតិ បជានាតិ និរាមិសំ ទុក្ខំ វេទនំ និរាមិសា ទុក្ខា វេទនាតិ បជានាតិ សាមិសំ អទុក្ខមសុខំ វេទនំ សាមិសា អទុក្ខមសុខា វេទនាតិ បជានាតិ និរាមិសំ អទុក្ខមសុខំ វេទនំ និរាមិសា អទុក្ខមសុខា វេទនាតិ បជានាតិ

មិនប្រកបដោយអាមិសៈក្តីថា បុគ្គលនេះទទួលអទុក្ខមសុខវេទនា មិនប្រកបដោយអាមិសៈ ៗ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះ ឲ្យជានិមិត្ត កំណត់នូវវេទនា ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវវេទនានោះ ឲ្យជានិមិត្ត កំណត់នូវវេទនា ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ៗ

(១៨៩) ចុះភិក្ខុ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយខាងក្នុងនិងខាងក្រៅ តើដូចម្តេច ៗ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវសុខវេទនាថា សុខវេទនា ដឹងច្បាស់ នូវទុក្ខវេទនាថា ទុក្ខវេទនា ដឹងច្បាស់នូវអទុក្ខមសុខវេទនាថា អទុក្ខមសុខវេទនា ដឹងច្បាស់នូវសុខវេទនា ប្រកបដោយអាមិសៈថា សុខវេទនា ប្រកបដោយអាមិសៈ ដឹងច្បាស់នូវសុខវេទនា មិនប្រកបដោយអាមិសៈថា សុខវេទនា មិនប្រកបដោយអាមិសៈ ដឹងច្បាស់នូវទុក្ខវេទនា ប្រកបដោយអាមិសៈថា ទុក្ខវេទនា ប្រកបដោយអាមិសៈ ដឹងច្បាស់នូវទុក្ខវេទនា មិនប្រកបដោយអាមិសៈថា ទុក្ខវេទនា មិនប្រកបដោយអាមិសៈ ដឹងច្បាស់នូវអទុក្ខមសុខវេទនា ប្រកបដោយអាមិសៈថា អទុក្ខមសុខវេទនា ប្រកបដោយអាមិសៈ ដឹងច្បាស់នូវអទុក្ខមសុខវេទនា មិនប្រកបដោយអាមិសៈថា អទុក្ខមសុខវេទនា មិនប្រកបដោយអាមិសៈ

ឯវំ ភិក្ខុ អជ្ឈត្តពហិទ្ធា វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

(១៩០) អនុបស្សីតិ ។ បេ ។ វិហរតីតិ ។ បេ ។ អាតាបីតិ ។ បេ ។ សម្បជានោតិ ។ បេ ។ សតិមាតិ ។ បេ ។ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ តត្ថ កតមោ លោកោ ។ សាយេវ វេទនា លោកោ បញ្ចបិ ឧបាទានក្ខន្ធា លោកោ អយំ វុច្ចតិ លោកោ ។ តត្ថ កតមា អភិជ្ឈា ។ យោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អភិជ្ឈា ។ តត្ថ កតមំ ទោមនស្សំ ។ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។

ភិក្ខុពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

[១៩០] សេចក្តីត្រង់ពាក្យថា ភិក្ខុពិចារណា ។បេ។ ពាក្យថា សម្រេចឥរិយាបថ ។បេ។ សេចក្តីត្រង់ពាក្យថា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ។បេ។ សេចក្តីត្រង់ពាក្យថា អ្នកដឹងខ្លួន ។បេ។ សេចក្តីត្រង់ពាក្យថា មានស្មារតី ។បេ។ សេចក្តីត្រង់ពាក្យថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។ សំនួរថា ចុះបណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ វេទនានោះឯង ឈ្មោះថាលោក ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំង នៃចិត្ត ណា នេះហៅថា អភិជ្ឈា ។ បណ្តាពាក្យទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផ័ស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផ័ស្ស នេះហៅថា ទោមនស្ស ។

## សតិប្បដ្ឋានវិភង្គេ សុត្តន្តភាជនីយំ

ឥតិ អយញ្ច អភិជ្ឈា ឥទញ្ច ទោមនស្សំ ឥមស្មឹ លោកេ វិនីតា ហោន្តិ បដិវិនីតា សន្តា សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។

### វេទនានុបស្សនានិទ្ទេសោ ។

(១៩១) កថញ្ច ភិក្ខុ អជ្ឈត្តំ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ មេ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ មេ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ មេ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ មេ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ មេ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ មេ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ មេ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ មេ ចិត្តន្តិ បជានាតិ

ពួកជនក្នុងលោកនេះ ភិក្ខុ ជាអ្នកទូន្មាន កំចាត់បង់ ស្ងប់ រម្ងាប់ ស្ងប់ ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហីនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ នូវអភិជ្ឈានិងទោមនស្សនេះ ក្នុងលោកនេះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបពោលថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។

ចប់ វេទនានុបស្សនានិទ្ទេស ។

(១៩១) ចុះភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្តខាងក្នុង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ រួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ រាយមាយ

មហគ្គតំ វា ចិត្តំ មហគ្គតំ មេ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ មេ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ មេ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ មេ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ មេ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ មេ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ មេ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ មេ ចិត្តន្តិ បជានាតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាវត្ថិតំ អវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វាវត្ថិតំ អវត្ថបេត្វា ពហិទ្ធា ចិត្តេ ចិត្តំ ឧបសំហរតិ ។

(១៩២) កថញ្ច ភិក្ខុ ពហិទ្ធា ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សរាគំ វាស្ស ចិត្តំ សរាគស្ស ចិត្តន្តិ បជានាតិ វីតរាគំ វាស្ស ចិត្តំ វីតរាគស្ស ចិត្តន្តិ បជានាតិ

នោះចិត្តជាមហគ្គតៈ (រូបាវចរនិងអរូបាវចរ) ក៏ដឹងច្បាស់ ថា ចិត្តរបស់អាត្មាអញ ជាមហគ្គតៈ នោះចិត្តមិនមែនជាមហគ្គតៈ (កាមាវចរ) ក៏ដឹងច្បាស់ ថា ចិត្តរបស់អាត្មាអញ មិនមែនជាមហគ្គតៈ នោះចិត្តជាសឧត្តរៈ (កាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ជាសឧត្តរៈ នោះចិត្តជាអនុត្តរៈ (រូបាវចរនិងអរូបាវចរ) ក៏ដឹងច្បាស់ ថា ចិត្តរបស់អាត្មាអញ ជាអនុត្តរៈ នោះចិត្តតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ តាំងនៅមាំ នោះចិត្តមិនតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ មិនតាំងនៅមាំ នោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ រួចស្រឡះ នោះចិត្តមិនទាន់រួចស្រឡះ (ចាកអាសវក្កិលេស) ក៏ដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ មិនទាន់រួចស្រឡះ ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវចិត្តនោះ ឲ្យជានិមិត្ត កំណត់នូវចិត្ត ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវចិត្តនោះ ឲ្យជានិមិត្ត កំណត់នូវចិត្ត ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងចិត្តខាងក្រៅ ។

(១៩២) ចុះភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្តខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ នោះចិត្តរបស់គេ ប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ប្រកបដោយរាគៈ នោះចិត្តរបស់គេ ប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ប្រាសចាករាគៈ

សទោសំ វាស្ស ចិត្តំ សទោសស្ស ចិត្តន្តិ បជានាតិ វីតទោសំ វាស្ស ចិត្តំ វីតទោសស្ស ចិត្តន្តិ បជានាតិ សមោហំ វាស្ស ចិត្តំ សមោហស្ស ចិត្តន្តិ បជានាតិ វីតមោហំ វាស្ស ចិត្តំ វីតមោហស្ស ចិត្តន្តិ បជានាតិ សង្ខិត្តំ វាស្ស ចិត្តំ សង្ខិត្តស្ស ចិត្តន្តិ បជានាតិ វិក្ខិត្តំ វាស្ស ចិត្តំ វិក្ខិត្តស្ស ចិត្តន្តិ បជានាតិ មហគ្គតំ វាស្ស ចិត្តំ មហគ្គតស្ស ចិត្តន្តិ បជានាតិ អមហគ្គតំ វាស្ស ចិត្តំ អមហគ្គតស្ស ចិត្តន្តិ បជានាតិ សឧត្តរំ វាស្ស ចិត្តំ សឧត្តរស្ស ចិត្តន្តិ បជានាតិ អនុត្តរំ វាស្ស ចិត្តំ អនុត្តរស្ស ចិត្តន្តិ បជានាតិ សមាហិតំ វាស្ស ចិត្តំ សមាហិតស្ស ចិត្តន្តិ បជានាតិ អសមាហិតំ វាស្ស ចិត្តំ អសមាហិតស្ស ចិត្តន្តិ បជានាតិ វិមុត្តំ វាស្ស ចិត្តំ វិមុត្តស្ស ចិត្តន្តិ បជានាតិ អវិមុត្តំ វាស្ស ចិត្តំ អវិមុត្តស្ស ចិត្តន្តិ បជានាតិ ។

ទោះចិត្តរបស់គេ ប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ប្រកបដោយទោសៈ ទោះចិត្តរបស់គេ ប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ប្រាសចាកទោសៈ ទោះចិត្តរបស់គេ ប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ប្រកបដោយមោហៈ ទោះចិត្តរបស់គេ ប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ប្រាសចាកមោហៈ ទោះចិត្តរបស់គេ រួញរា ក៏ដឹងច្បាស់ថា ចិត្តរបស់គេ រួញរា ទោះចិត្តរបស់គេរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ រាយមាយ ទោះចិត្តរបស់គេ ជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ជាមហគ្គតៈ ទោះចិត្តរបស់គេ មិនមែនជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ មិនមែនជាមហគ្គតៈ ទោះចិត្តរបស់គេ ជាសឧត្តរៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ជាសឧត្តរៈ ទោះចិត្តរបស់គេ ជាអនុត្តរៈ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ ជាអនុត្តរៈ ទោះចិត្តរបស់គេ តាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ តាំងនៅមាំ ទោះចិត្តរបស់គេ មិនតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ មិនតាំងនៅមាំ ទោះចិត្តរបស់គេ រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ រួចស្រឡះ ទោះចិត្តរបស់គេ មិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរបស់គេ មិនទាន់រួចស្រឡះ ។

សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាវត្ថិតំ អវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វាវត្ថិតំ អវត្ថបេត្វា អជ្ឈត្ត-ពហិទ្ធា ចិត្តេ ចិត្តំ ឧបសំហរតិ ។

(១៩៣) កថញ្ច ភិក្ខុ អជ្ឈត្តពហិទ្ធា ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជា-នាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ

ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវចិត្តនោះឲ្យជានិមិត្ត កំណត់នូវចិត្ត ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន ចំពោះចិត្តនោះឲ្យជានិមិត្ត កំណត់នូវចិត្ត ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងចិត្ត ខាងក្នុងនិងខាងក្រៅ ។

( ១៩៣ ) ចុះភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្ត ខាងក្នុងនិងខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ទោះចិត្តជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ទោះចិត្តមិនមែនជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ទោះចិត្តជាសឧត្តរៈ ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ទោះចិត្តជាអនុត្តរៈ ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ទោះចិត្តតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ

អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ឯវំ ភិក្ខុ អជ្ឈត្តពហិទ្ធា ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

( ១៩៤ ) អនុបស្សីតិ ។បេ។ វិហរតីតិ ។បេ។ អាតាបីតិ ។បេ។ សម្បជានោតិ ។បេ។ សតិមាតិ ។បេ។ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។ តត្ថ កតមោ លោកោ ។ តំយេវ ចិត្តំ លោកោ បញ្ចបិ ឧបាទានក្ខន្ធា លោកោ អយំ វុច្ចតិ លោកោ ។ តត្ថ កតមា អភិជ្ឈា ។ យោ រាគោ សារាគោ ។បេ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អភិជ្ឈា ។ តត្ថ កតមំ ទោមនស្សំ ។ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។

ទោះចិត្តមិនតាំងនៅមាំ ក៏ដឹងច្បាស់ថា ចិត្តមិនតាំងនៅមាំ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ទោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្ត ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់ អភិជ្ឈានិងទោម-នស្សក្នុងលោក យ៉ាងនេះឯង ។

[ ១៩៨ ] សេចក្តីត្រង់ពាក្យថា ភិក្ខុ ពិចារណា ។ បេ ។ សេចក្តីត្រង់ពាក្យថា សម្រេចឥរិយាបថ ។ បេ ។ សេចក្តីត្រង់ពាក្យថា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ។ បេ ។ សេចក្តីត្រង់ពាក្យថា ជាអ្នកដឹងខ្លួន ។ បេ ។ សេចក្តីត្រង់ពាក្យថា មានស្មារតី ។ បេ ។ សេចក្តីត្រង់ពាក្យថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។ សំនួរថា បណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ ចិត្តនោះឯង ឈ្មោះថា លោក ឧបាទានក្ខន្ធទាំង ៥ ឈ្មោះថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំង នៃចិត្ត ណា នេះហៅថា អភិជ្ឈា ។ បណ្តាពាក្យទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខ ដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនា មិនជាទីត្រេកអរ ដែលកើតអំពីចេតោសម្ផស្ស ណា នេះហៅថា ទោមនស្ស ។

ឥតិ អយញ្ច អភិជ្ឈា ឥទញ្ច ទោមនស្សំ ឥមស្មិំ លោកេ វិជិតា ហោន្តិ បដិវិជិតា សន្តា សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។

ចិត្តានុបស្សនានិទ្ទេសោ ។

(១៩៨) កថញ្ច ភិក្ខុ អជ្ឈត្តំ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ សន្តំ វា អជ្ឈត្តំ ព្យាបាទំ ។ បេ ។ សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ ។ បេ ។

អភិជ្ឈានេះផង ទោមនស្សនេះផង រមែងមាន ដោយប្រការដូច្នេះ ពួកជនក្នុងលោកនេះ ជាអ្នកទូន្មាន កំចាត់បង់ ស្ងប់ រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហិនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ ព្រោះហេតុនោះ ទើបពោលថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។

ចប់ ចិត្តានុបស្សនានិទ្ទេស ។

[១៩៨] ចុះភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយខាងក្នុង តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវកាមច្ឆន្ទៈខាងក្នុង កាលមាន ថា កាមច្ឆន្ទៈខាងក្នុងរបស់អាត្មាអញមាន ឬ ដឹងច្បាស់នូវកាមច្ឆន្ទៈខាងក្នុង កាលមិនមាន ថា កាមច្ឆន្ទៈខាងក្នុងរបស់អាត្មាអញមិនមាន ការកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅ នៃកាមច្ឆន្ទៈ ដែលខ្លួនលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ភិក្ខុ ដឹងច្បាស់ នូវព្យាបាទខាងក្នុង កាលមាន ។ បេ ។ នូវថីនមិទ្ធៈខាងក្នុង កាលមាន ។ បេ ។

សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ ។ បេ ។ សន្តំ វា
អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជា-
នាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ
វិចិកិច្ឆាតិ បជានាតិ យថា ច អនុប្បន្នាយ វិចិ-
កិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា
ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច
បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយ-
តិំ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ
វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ សតិ-
សម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ សតិ-
សម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ
បជានាតិ យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈ-
ង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា
ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ
ហោតិ តញ្ច បជានាតិ សន្តំ វា អជ្ឈត្តំ ធម្មវិច-
យសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ វីរិយសម្ពោ-
ជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ បីតិសម្ពោជ្ឈង្គំ ។ បេ ។

នូវឧទ្ធច្ចកុក្កុច្ចៈខាងក្នុង កាលមាន ។បេ។ នូវវិចិកិច្ឆាខាងក្នុង កាលមាន ថា វិចិកិច្ឆាខាងក្នុងរបស់អាត្មាអញមាន ឬ ដឹងច្បាស់ នូវវិចិកិច្ឆាខាងក្នុង កាលមិនមាន ថា វិចិកិច្ឆាខាងក្នុងរបស់អាត្មាអញមិនមាន ការកើតឡើង នៃវិចិកិច្ឆា ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការមិនកើតតទៅ នៃវិចិកិច្ឆាដែលខ្លួនលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ភិក្ខុ ដឹងច្បាស់នូវសតិសម្ពោជ្ឈង្គខាងក្នុង កាលមាន ថា សតិសម្ពោជ្ឈង្គខាងក្នុង របស់អាត្មាអញមាន ឬ ដឹងច្បាស់ នូវសតិ-សម្ពោជ្ឈង្គខាងក្នុង កាលមិនមាន ថា សតិសម្ពោជ្ឈង្គខាងក្នុង របស់អាត្មាអញមិនមាន ការកើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការពេញលេញដោយភាវនា នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ដឹងច្បាស់ នូវធម្មវិចយ-សម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវវីរិយសម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។ នូវបីតិសម្ពោជ្ឈង្គខាងក្នុង កាលមាន ។បេ។

សន្តំ វា អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ ឧបេក្ខាស-ម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧបេក្ខា-សម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោ-ជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជានាតិ ។ សោ តំ និមិត្តំ អា-សេវតិ ភាវេតិ ពហុលីករោតិ ស្វវត្ថិតំ អវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វវត្ថិតំ អវត្ថបេត្វា ពហិទ្ធា ធម្មេសុ ចិត្តំ ឧប-សំហរតិ ។

(១៩៦) កថញ្ច ភិក្ខុ ពហិទ្ធា ធម្មេសុ ធម្មា-នុបស្សី វិហរតិ ។ ឥធ ភិក្ខុ សន្តំ វាស្ស កាមច្ឆន្ទំ អត្ថិស្ស កាមច្ឆន្ទោតិ បជានាតិ អសន្តំ វាស្ស កាមច្ឆន្ទំ នត្ថិស្ស កាមច្ឆន្ទោតិ បជានាតិ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច

នូវបស្សទ្ធិសម្ពោជ្ឈង្គខាងក្នុង កាលមាន ។ បេ ។ នូវសមាធិសម្ពោជ្ឈង្គខាងក្នុង កាលមាន ។ បេ ។ នូវឧបេក្ខាសម្ពោជ្ឈង្គខាងក្នុង កាលមាន ថា ឧបេក្ខាសម្ពោជ្ឈង្គខាងក្នុង របស់អាត្មាអញមាន ឬដឹងច្បាស់នូវឧបេក្ខាសម្ពោជ្ឈង្គខាងក្នុង កាលមិនមាន ថា ឧបេក្ខាសម្ពោជ្ឈង្គខាងក្នុង របស់អាត្មាអញ មិនមាន ការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការពេញលេញដោយភាវនា នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ភិក្ខុនោះរមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះឲ្យជានិមិត្ត កំណត់នូវធម៌ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះឲ្យជានិមិត្ត កំណត់នូវធម៌ ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងធម៌ទាំងឡាយជាខាងក្រៅ ។

[១៩៦] ចុះភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយជាខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវកាមច្ឆន្ទៈរបស់គេ កាលមាន ថា កាមច្ឆន្ទៈរបស់គេមាន ឬ ដឹងច្បាស់នូវកាមច្ឆន្ទៈរបស់គេ កាលមិនមាន ថា កាមច្ឆន្ទៈរបស់គេ មិនមាន ការកើតឡើង នៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ដោយហេតុណា

បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ សន្តំ វា អស្ស ព្យាបាទំ ។ បេ ។ សន្តំ វា អស្ស ថីនមិទ្ធំ ។ បេ ។ សន្តំ វា អស្ស ឧទ្ធច្ចកុក្កុច្ចំ ។ បេ ។ សន្តំ វា អស្ស វិចិកិច្ឆំ អត្ថិស្ស វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អស្ស វិចិកិច្ឆំ នត្ថិស្ស វិចិកិច្ឆាតិ បជានាតិ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អស្ស សតិសម្ពោជ្ឈង្គំ អត្ថិស្ស សតិសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អស្ស សតិសម្ពោជ្ឈង្គំ នត្ថិស្ស សតិសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជានាតិ សន្តំ វា អស្ស ធម្មវិចយសម្ពោជ្ឈង្គំ ។ បេ ។

ក៏ដឹងច្បាស់ នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការមិនកើតតទៅនៃកាមច្ឆន្ទៈ ដែលគេលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ដឹងច្បាស់ នូវព្យាបាទរបស់គេ កាលមាន ។បេ។ នូវថីនមិទ្ធៈរបស់គេ កាលមាន ។បេ។ នូវឧទ្ធច្ចកុក្កុច្ចៈរបស់គេ កាលមាន ។បេ។ នូវវិចិកិច្ឆារបស់គេ កាលមាន ថា វិចិកិច្ឆារបស់គេមាន ឬ ដឹងច្បាស់ នូវវិចិកិច្ឆារបស់គេ កាលមិនមាន ថា វិចិកិច្ឆារបស់គេមិនមាន ការកើតឡើង នៃវិចិកិច្ឆាដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការមិនកើតតទៅ នៃវិចិកិច្ឆាដែលគេលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ភិក្ខុ ដឹងច្បាស់ នូវសតិសម្ពោជ្ឈង្គរបស់គេ កាលមាន ថា សតិសម្ពោជ្ឈង្គរបស់គេមាន ឬ ដឹងច្បាស់ នូវសតិសម្ពោជ្ឈង្គរបស់គេ កាលមិនមាន ថា សតិសម្ពោជ្ឈង្គរបស់គេ មិនមាន ការកើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការពេញលេញដោយភាវនា នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ភិក្ខុ ដឹងច្បាស់ នូវធម្មវិចយសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។

សន្តំ វាស្ស វីរិយសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វាស្ស បីតិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វាស្ស បស្សទ្ធិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វាស្ស សមាធិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វាស្ស ឧបេក្ខាសម្ពោជ្ឈង្គំ អត្ថិស្ស ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វាស្ស ឧបេក្ខាសម្ពោជ្ឈង្គំ នត្ថិស្ស ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជានាតិ ។ សោ តំ និមិត្តំ អាសេវតិ ភាវេតិ ពហុលីករោតិ ស្វាវត្ថិតំ អវត្ថបេតិ សោ តំ និមិត្តំ អាសេវិត្វា ភាវេត្វា ពហុលីករិត្វា ស្វាវត្ថិតំ អវត្ថបេត្វា អជ្ឈត្តពហិទ្ធា ធម្មេសុ ចិត្តំ ឧបសំហរតិ ។

(១៩៧) កថញ្ច ភិក្ខុ អជ្ឈត្តពហិទ្ធា ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខុ សន្តំ វា កាមច្ឆន្ទំ អត្ថិ កាមច្ឆន្ទោតិ បជានាតិ អសន្តំ វា កាមច្ឆន្ទំ នត្ថិ កាមច្ឆន្ទោតិ បជានាតិ

នូវវីរិយសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ នូវបីតិសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ នូវបស្សទ្ធិសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ នូវសមាធិសម្ពោជ្ឈង្គរបស់គេ កាលមាន ។បេ។ ដឹងច្បាស់ នូវឧបេក្ខាសម្ពោជ្ឈង្គរបស់គេ កាលមាន ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់គេមាន ឬ ដឹងច្បាស់នូវឧបេក្ខាសម្ពោជ្ឈង្គរបស់គេ កាលមិនមាន ថា ឧបេក្ខាសម្ពោជ្ឈង្គរបស់គេមិនមាន ការកើតឡើង នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការពេញលេញដោយភាវនា នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ភិក្ខុនោះ រមែងគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះឲ្យជានិមិត្ត កំណត់នូវធម៌ដែលខ្លួនកំណត់ទុកដោយល្អ ភិក្ខុនោះ លុះគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌នោះឲ្យជានិមិត្ត កំណត់នូវធម៌ដែលខ្លួនកំណត់ទុកដោយល្អហើយ រមែងប្រមូលមកនូវចិត្ត ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅ ។

(១៩៧) ចុះភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅ តើដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវកាមច្ឆន្ទៈ កាលមាន ថាកាមច្ឆន្ទៈមាន ឬដឹងច្បាស់នូវកាមច្ឆន្ទៈ កាលមិនមាន ថាកាមច្ឆន្ទៈមិនមាន

យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ សន្តំ វា ព្យាបាទំ ។ បេ ។ សន្តំ វា ថីនមិទ្ធំ ។ បេ ។ សន្តំ វា ឧទ្ធច្ចកុក្កុច្ចំ ។ បេ ។ សន្តំ វា វិចិកិច្ឆំ អត្ថិ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា វិចិកិច្ឆំ នត្ថិ វិចិកិច្ឆាតិ បជានាតិ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា សតិសម្ពោជ្ឈង្គំ អត្ថិ សតិសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា សតិសម្ពោជ្ឈង្គំ នត្ថិ សតិសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ

ការកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការមិនកើតតទៅ នៃកាមច្ឆន្ទៈ ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ភិក្ខុដឹងច្បាស់ នូវព្យាបាទ កាលមាន ។ បេ ។ នូវថីនមិទ្ធៈ កាលមាន ។ បេ ។ នូវឧទ្ធច្ចកុក្កុច្ចៈ កាលមាន ។ បេ ។ នូវវិចិកិច្ឆា កាលមាន ថា វិចិកិច្ឆាមាន ឬ ដឹងច្បាស់ នូវវិចិកិច្ឆា កាលមិនមាន ថា វិចិកិច្ឆាមិនមាន ការកើតឡើងនៃវិចិកិច្ឆា ដែលមិនទាន់កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ការមិនកើតតទៅ នៃវិចិកិច្ឆា ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង ។ ភិក្ខុដឹងច្បាស់ នូវសតិសម្ពោជ្ឈង្គ កាលមាន ថា សតិសម្ពោជ្ឈង្គមាន ឬ ដឹងច្បាស់ នូវសតិសម្ពោជ្ឈង្គ កាលមិនមាន ថា សតិសម្ពោជ្ឈង្គ មិនមាន ការកើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង

យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជានាតិ សន្តំ វា ធម្មវិចយសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា វីរិយសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា បីតិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា បស្សទ្ធិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា សមាធិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា ឧបេក្ខាសម្ពោជ្ឈង្គំ អត្ថិ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា ឧបេក្ខាសម្ពោជ្ឈង្គំ នត្ថិ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជានាតិ ។ ឯវំ ភិក្ខុ អជ្ឈត្តំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

( ១៩៨ ) អនុបស្សីតិ តត្ថ កតមា អនុបស្សនា ។ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ អយំ វុច្ចតិ

ការពេញលេញដោយការនា នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ភិក្ខុដឹងច្បាស់ នូវធម្មវិចយសម្ពោជ្ឈង្គ កាលមាន ។ បេ ។ នូវវីរិយសម្ពោជ្ឈង្គ កាលមាន ។ បេ ។ នូវបីតិសម្ពោជ្ឈង្គ កាលមាន ។ បេ ។ នូវបស្សទ្ធិសម្ពោជ្ឈង្គ កាលមាន ។ បេ ។ នូវសមាធិសម្ពោជ្ឈង្គ កាលមាន ។បេ។ នូវឧបេក្ខាសម្ពោជ្ឈង្គ កាលមាន ថា ឧបេក្ខាសម្ពោជ្ឈង្គមាន ឬ ដឹងច្បាស់នូវឧបេក្ខាសម្ពោជ្ឈង្គ កាលមិនមាន ថា ឧបេក្ខាសម្ពោជ្ឈង្គមិនមាន ការកើតឡើង នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការពេញលេញដោយការនា នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅ សម្រេចឥរិយាបថ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់អភិជ្ឈា និងទោមនស្ស ក្នុងលោក យ៉ាងនេះឯង ។

(១៩៨) សេចក្តីត្រង់ពាក្យថា ភិក្ខុពិចារណា ។ ប្រស្នាថា ចុះបណ្តាពាក្យទាំងនោះ ការពិចារណា តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ នេះហៅថា

អនុបស្សនា ឥមាយ អនុបស្សនាយ ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ អនុបស្សីតិ ។

(១៩៩) វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

(២០០) អាតាបីតិ តត្ថ កតមំ អាតប្បំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ អាតប្បំ ឥមិនា អាតប្បេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ អាតាបីតិ ។

(២០១) សម្បជានោតិ តត្ថ កតមំ សម្បជញ្ញំ ។ យា បញ្ញា បជាននា ។ បេ ។ អមោហោ ធម្មវិចយោ សម្មាទិដ្ឋិ ឥទំ វុច្ចតិ សម្បជញ្ញំ ឥមិនា សម្បជញ្ញេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ សម្បជានោតិ ។

ការពិចារណា ភិក្ខុជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយបញ្ញាជាគ្រឿងពិចារណានេះ ព្រោះហេតុនោះ ទើបពោលថា ភិក្ខុពិចារណា ។

[ ១៩៩ ] សេចក្តីត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្ត រក្សា រស់នៅ ញុំាងអត្តភាពឲ្យរស់នៅ ត្រាច់ទៅ នៅ សម្រាក ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[ ២០០ ] សេចក្តីត្រង់ពាក្យថា អ្នកមានព្យាយាមជាគ្រឿងដុតកំដៅកិលេស ។ សំនួរថា ចុះបណ្តាពាក្យទាំងនោះ ការព្យាយាមជាគ្រឿងដុតកំដៅកិលេស តើដូចម្តេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សេចក្តីព្យាយាមត្រូវ ណា នេះហៅថា សេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស ភិក្ខុ ជាអ្នកព្រមព្រៀង ។ បេ ។ ប្រកប ដោយព្យាយាមជាគ្រឿងដុតកំដៅកិលេសនេះ ព្រោះហេតុនោះ ទើបពោលថា មានព្យាយាមជាគ្រឿងដុកកំដៅកិលេស ។

[ ២០១ ] សេចក្តីត្រង់ពាក្យថា ជាអ្នកដឹងខ្លួន ។ សំនួរថា ចុះបណ្តាពាក្យទាំងនោះ ការដឹងខ្លួន តើដូចម្តេច ។ បញ្ញា ការដឹងច្បាស់ ។ បេ ។ សេចក្តីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ណា នេះហៅថា ការដឹងខ្លួន ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកប ដោយការដឹងខ្លួននេះ ព្រោះហេតុនោះ ទើបពោលថា ជាអ្នកដឹងខ្លួន ។

[ ២០២ ] សតិមាតិ តត្ថ កតមា សតិ ។ យា សតិ អនុស្សតិ ។ បេ ។ សម្មាសតិ អយំ វុច្ចតិ សតិ ឥមាយ សតិយា ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ សតិមាតិ ។

[ ២០៣ ] វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។ តត្ថ កតមោ លោកោ ។ តេវ ធម្មា លោកោ បញ្ចបិ ឧបាទានក្ខន្ធា លោកោ អយំ វុច្ចតិ លោកោ ។ តត្ថ កតមា អភិជ្ឈា ។ យោ រាគោ សារាគោ ។ បេ ។ ចិត្តស្ស សារាគោ អយំ វុច្ចតិ អភិជ្ឈា ។ តត្ថ កតមំ ទោមនស្សំ ។ យំ ចេតសិកំ អសាតំ ចេតសិកំ ទុក្ខំ ចេតោសម្ផស្សជំ អសាតំ ទុក្ខំ វេទយិតំ ចេតោសម្ផស្សជា អសាតា ទុក្ខា វេទនា ឥទំ វុច្ចតិ ទោមនស្សំ ។ ឥតិ អយញ្ច អភិជ្ឈា ឥទញ្ច

(២០២) សេចក្តីត្រង់ពាក្យថា មានស្មារតី ។ សំនួរថា ចុះបណ្តាពាក្យទាំងនោះ ស្មារតី តើដូចម្តេច ។ គឺ ការនឹករឭក ការនឹករឿយ ៗ ។ បេ ។ ការរឭកត្រូវ ណា នេះហៅថា ស្មារតី ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបដោយស្មារតីនេះ ព្រោះហេតុនោះ ទើបពោលថា មានស្មារតី ។

(២០៣) សេចក្តីត្រង់ពាក្យថា កំចាត់បង់អភិជ្ឈានិងទោមនស្សក្នុងលោក ។ សំនួរថា ចុះបណ្តាពាក្យទាំងនោះ លោក តើដូចម្តេច ។ ធម៌ទាំងឡាយនោះឯង ហៅថា លោក ឧបាទានក្ខន្ធទាំង ៥ ហៅថា លោក នេះហៅថា លោក ។ បណ្តាពាក្យទាំងនោះ អភិជ្ឈា តើដូចម្តេច ។ តម្រេក តម្រេកខ្លាំង ។ បេ ។ តម្រេកខ្លាំង នៃចិត្ត ណា នេះហៅថា អភិជ្ឈា ។ បណ្តាពាក្យទាំងនោះ ទោមនស្ស តើដូចម្តេច ។ សេចក្តីមិនត្រេកអរ ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនជាទីត្រេកអរ ជាទុក្ខដែលកើតអំពីចេតោសម្ផស្ស ទុក្ខវេទនាមិនជាទីត្រេកអរ ដែលកើតអំពីចេតោ-សម្ផស្ស ណា នេះហៅថា ទោមនស្ស ។ ភិក្ខុ ជាអ្នកទូន្មាន កំចាត់បង់

ទោមនស្សំ ឥមម្ហិ លោកេ វិនីតា ហោន្តិ បដិវិនី-តា សន្តា សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តី-កតា តេន វុច្ចតិ វិនេយ្យ លោកេ អភិជ្ឈា-ទោមនស្សន្តិ ។

ធម្មានុបស្សនានិទ្ទេសោ ។

សុត្តន្តភាជនីយំ ។

( ២០៤ ) ចត្តារោ សតិប្បដ្ឋានា ឥធ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ វេទនាសុ វេទ-នានុបស្សី វិហរតិ ចិត្តេ ចិត្តានុបស្សី វិហរតិ ធម្មេសុ ធម្មានុបស្សី វិហរតិ ។

( ២០៥ ) កថញ្ច ភិក្ខុ កាយេ កាយានុ-បស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិ-យា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ កាយេ កាយានុបស្សី យា តស្មឹ សមយេ

ស្ងប់ រម្ងាប់ ស្ងប់ឈឹង ធ្វើឲ្យវិនាស ធ្វើឲ្យសាបសូន្យ ឲ្យដល់នូវការខូចខាត ឲ្យដល់នូវការហិនហោច ឲ្យរីងស្ងួត ឲ្យហួតហែង ធ្វើឲ្យបាត់បង់ នូវអភិជ្ឈា និងទោមនស្សនេះ ដោយប្រការដូច្នេះ ក្នុងលោកនេះ ព្រោះហេតុនោះ ទើបពោលថា កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ។

ចប់ ធម្មានុបស្សនានិទ្ទេស ។

ចប់ សុត្តន្តភាជនីយ ។

[ ២០៤ ] សតិប្បដ្ឋាន ៤ ។ គឺភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយ ក្នុងកាយ ១ ពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ១ ពិចារណា នូវចិត្ត ក្នុងចិត្ត ១ ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ១ ។

[ ២០៥ ] ចុះភិក្ខុ ពិចារណា នូវកាយ ក្នុងកាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ( ភិក្ខុនេះ ) ឈ្មោះថា ពិចារណានូវកាយ ក្នុងកាយ ក្នុងសម័យនោះ

សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិបដ្ឋានំ អវសេសា ធម្មា សតិបដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ វេទនាសុ វេទនានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិបដ្ឋានំ អវសេសា ធម្មា សតិបដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ ចិត្តេ ចិត្តានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។

ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា (ភិក្ខុនេះ) ឈ្មោះថាពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ក្នុងសម័យនោះ ការនឹករឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋានធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយ សតិប្បដ្ឋាន ។ ចុះភិក្ខុ ពិចារណានូវចិត្ត ក្នុងចិត្ត តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា (ភិក្ខុនេះ) ឈ្មោះថា ពិចារណានូវចិត្ត ក្នុងចិត្ត ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។

សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ ធម្មេសុ ធម្មានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។បេ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។ តត្ថ កតមំ សតិប្បដ្ឋានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ ធម្មេសុ

ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុ ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា (ភិក្ខុនេះ) ឈ្មោះថាពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ បណ្តាធម៌ទាំងនោះ សតិប្បដ្ឋាន តើដូចម្តេច ។ ក្នុងសម័យ ណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា (ភិក្ខុនេះ) ឈ្មោះថា ពិចារណា នូវធម៌

ធម្មានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។បេ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិបដ្ឋានំ អវសេសា ធម្មា សតិបដ្ឋានសម្បយុត្តា ។

(២០៦) ចត្តារោ សតិបដ្ឋានា ។ ឥធ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ វេទនាសុ វេទនានុបស្សី វិហរតិ ចិត្តេ ចិត្តានុបស្សី វិហរតិ ធម្មេសុ ធម្មានុបស្សី វិហរតិ ។

(២០៧) កថញ្ច ភិក្ខុ កាយេ កាយានុស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ

ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។បេ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។

(២០៦) សតិប្បដ្ឋាន ៤ ។ ភិក្ខុក្នុងសាសនានេះ ពិចារណា នូវកាយ ក្នុងកាយ ១ ពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ១ ពិចារណា នូវចិត្ត ក្នុងចិត្ត ១ ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ១ ។

(២០៧) ចុះភិក្ខុ ពិចារណានូវកាយ ក្នុងកាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យា-និកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈ ក៏មាន ។បេ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន

ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ កាយេ កាយានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ វេទនាសុ វេទនានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ

ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចំរើនហើយ (ភិក្ខុនេះ) ឈ្មោះថា ពិចារណានូវកាយ ក្នុងកាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។ បេ ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចំរើនហើយ (ភិក្ខុនេះ) ឈ្មោះថាពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ ក្នុងសម័យនោះ ការរឭក ការរឭកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ

មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិបដ្ឋានំ អវសេសា ធម្មា សតិបដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ ចិត្តេ ចិត្តានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។ បេ ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិបដ្ឋានំ អវសេសា ធម្មា សតិបដ្ឋានសម្បយុត្តា ។ កថញ្ច ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ

ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណា នូវចិត្ត ក្នុងចិត្ត តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកៈ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្សៈក៏មាន ។ បេ ។ អវិក្ខេបៈ ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ជាវិបាក ព្រោះភាពនៃលោកុត្តរ-កុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ ចំរើនហើយ (ភិក្ខុនេះ) ឈ្មោះថា ពិចារណា នូវចិត្ត ក្នុងចិត្ត ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយ ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ ចុះភិក្ខុពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ

លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ ធម្មេសុ ធម្មានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។បេ។ សម្មាសតិ សតិសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិប្បដ្ឋានំ អវសេសា ធម្មា សតិប្បដ្ឋានសម្បយុត្តា ។ តត្ថ កតមំ សតិប្បដ្ឋានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។

បំរើនលោកុត្តរជ្ឈាន ជានិយ្យានិក: ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដ:) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្ស: ក៏មាន ។ បេ ។ អវិក្ខេប: ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធា-ភិញ្ញា ជាសុញ្ញត: ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ បំរើនហើយ (ភិក្ខុនេះ) ឈ្មោះថា ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭក ការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។ បណ្ដាធម៌ទាំងនោះ សតិប្បដ្ឋាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ បំរើនលោកុត្តរជ្ឈាន ជានិយ្យានិក: ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដ:) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ផស្ស: ក៏មាន ។ បេ ។

អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ ធម្មេសុ ធម្មានុបស្សី យា តស្មឹ សមយេ សតិ អនុស្សតិ ។បេ។ សម្មាសតិ សតិសម្ពោជ្ឈង្គំ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សតិបដ្ឋានំ អវសេសា ធម្មា សតិបដ្ឋានសម្បយុត្តា ។

## អភិធម្មភាជនីយំ ។

(២០៨) ចត្តារោ សតិបដ្ឋានា ឥធ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ចតុន្នំ សតិបដ្ឋានានំ

អវិក្ខេប: ក៏មាន ធម៌ទាំងនេះ ជាកុសល ភិក្ខុ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញត: ជាវិបាក ព្រោះភាពនៃលោកុត្តរកុសលជ្ឈាននោះឯង ដែលលោកបានធ្វើហើយ បំរើនហើយ (ភិក្ខុនេះ) ឈ្មោះថាពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ ក្នុងសម័យនោះ ការរឭកការនឹកឃើញ ។ បេ ។ ការរឭកត្រូវ សតិសម្ពោជ្ឈង្គ ជាអង្គនៃមគ្គរាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សតិប្បដ្ឋាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយសតិប្បដ្ឋាន ។

ចប់ អភិធម្មភាជនីយ ។

[២០៨] សតិប្បដ្ឋាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ពិចារណា នូវកាយ ក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ពិចារណា នូវវេទនា ក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ពិចារណា នូវចិត្ត ក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កំចាត់បង់អភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ពិចារណា នូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ១ ។ បណ្ដាសតិប្បដ្ឋានទាំង ៤

សតិបដ្ឋានវិភង្គ បញ្ហាបុច្ឆកំ

កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។បេ។ កតិ សរណា កតិ អរណា ។

(២០៩) សិយា កុសលា សិយា អព្យាកតា សិយា សុខាយ វេទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា សិយា វិបាកា សិយា វិបាកធម្មធម្មា អនុបាទិន្នុបាទានិយា អសង្កិលិដ្ឋាសង្កិលេសិកា សិយា សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា អវិតក្កាវិចារា សិយា បីតិសហគតា សិយា សុខសហគតា សិយា ឧបេក្ខាសហគតា នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា សិយា អបចយគាមិនោ សិយា នេវាចយគាមិនាបចយគាមិនោ សិយា សេក្ខា សិយា អសេក្ខា អប្បមាណា អប្បមាណារម្មណា បណីតា សិយា សម្មត្តនិយតា សិយា អនិយតា មគ្គារម្មណា សិយា មគ្គហេតុកា សិយា មគ្គាធិបតិនោ សិយា

## សតិប្បដ្ឋានវិភង្គ បញ្ហាបុច្ឆកៈ

សតិប្បដ្ឋាន ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈ(១)ប៉ុន្មាន ជាអរណៈ(២)ប៉ុន្មាន ។

[ ២០៩ ] សតិប្បដ្ឋាន ៤ ជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនាក៏មាន ជាវិបាកក៏មាន ជាធម៌មានវិបាកជាប្រក្រតី តែមិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន តែមិនសៅហ្មង ទាំងមិនគួរដល់សេចក្ដីសៅហ្មង ក៏មាន ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ ក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ក៏មាន មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ក៏មាន ប្រឡំដោយបីតិ ក៏មាន ប្រឡំដោយសុខ ក៏មាន ប្រឡំដោយឧបេក្ខា ដែលមិនគួរលះ ដោយទស្សនៈ មិនគួរលះ ដោយភាវនា មានហេតុដែលមិនគួរលះ ដោយទស្សនៈ ទាំងមិនគួរលះ ដោយភាវនា ក៏មាន ដល់នូវការមិនសន្សំ ក៏មាន មិនដល់នូវការសន្សំកពូនឡើង ទាំងមិនដល់នូវការមិនសន្សំ ក៏មាន ជាសេក្ខៈ ក៏មាន ជាអសេក្ខៈ ដែលមិនមានប្រមាណ មានអារម្មណ៍ប្រមាណមិនបាន ជាធម៌ដ៏ប្រសើរ ក៏មាន មានសភាពត្រូវនិងទៀង ក៏មាន មិនទៀង ដែលមានមគ្គជាអារម្មណ៍ ក៏មាន មានមគ្គជាហេតុ ក៏មាន មានមគ្គជាអធិបតី ក៏មាន

---

១ ប្រែថា ប្រកបដោយធម៌ជាសត្រូវ ឬ ញុំាងសត្វឲ្យកន្ទក់កន្ទេញ ឲ្យស្តាយស្រណោះ ។ ២ ប្រែថា ធម៌មិនមែនជាសត្រូវ ឬ មិនញុំាងសត្វឲ្យកន្ទក់កន្ទេញ ឬ មិនឲ្យស្តាយស្រណោះ ។

ន វត្តព្វា មគ្គហេតុកាតិបិ មគ្គាធិបតិនោតិបិ សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[២១០] ន ហេតូ សហេតុកា ហេតុសម្បយុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ

មិនគួរពោលថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផង ក៏មាន កើតឡើងហើយ ក៏មាន មិនទាន់កើតឡើងហើយ ក៏មាន ប្រុងនឹងកើតឡើង ក៏មាន ជាអតីត ក៏មាន ជាអនាគត ក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផង ក៏មាន ជាខាងក្នុង ក៏មាន ជាខាងក្រៅ ក៏មាន ជាខាងក្នុងទាំងខាងក្រៅ ដែលមានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ក៏មាន ។

(២១០) សតិប្បដ្ឋាន ៤ មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ សតិប្បដ្ឋាន ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គួរដឹងដោយវិញ្ញាណណាមួយ មិនគួរដឹងដោយវិញ្ញាណណាមួយ ។ សតិប្បដ្ឋាន ៤ មិនមែនអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា ជាអាសវៈ ទាំង

សាសវា ចាតិបិ សាសវា ចេវ នោ ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។បេ។ នោ គន្ថា ។បេ។ នោ ឱឃា ។បេ។ នោ យោគា ។បេ។ នោ នីវរណា ។បេ។ នោ បរាមាសា ។បេ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។បេ។ នោ កិលេសា ។បេ។ ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សិយា សវិតក្កា សិយា អវិតក្កា សិយា សវិចារា សិយា អវិចារា សិយា

ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈផងទេ មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនអាសវៈផងឡើយ គឺជាធម៌ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ សតិប្បដ្ឋាន ៤ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែនឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ច្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមចិត្ត ច្រឡំទាំងតាំងឡើងដោយចិត្ត ច្រឡំទាំងតាំងឡើងទាំងកើតជាមួយនឹងចិត្ត ច្រឡំទាំងតាំងឡើងទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា ដែលកិលេសមានតណ្ហាជាដើមមិនកាន់យក ។ សតិប្បដ្ឋាន ៤ មិនមែនឧបាទាន ។ បេ ។ មិនមែនកិលេស ។ បេ ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រកបដោយវិតក្កៈ ក៏មាន មិនមានវិតក្កៈ ក៏មាន ប្រកបដោយវិចារៈ ក៏មាន មិនមានវិចារៈ ក៏មាន

សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយាបន្នា សិយា និយ្យានិកា សិយា អនិយ្យានិកា សិយា និយតា សិយា អនិយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

សតិប្បដ្ឋានវិភង្គោ សមត្តោ ។

ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រឡំដោយបីតិក៏មាន មិនប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខក៏មាន មិនប្រឡំដោយសុខក៏មាន ប្រឡំដោយឧបេក្ខាក៏មាន មិនប្រឡំដោយឧបេក្ខា តែមិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែនអរូបាវចរ ជាអបរិយាបន្នៈក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈ ជាអនុត្តរៈ ជាអរណៈក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ សតិប្បដ្ឋានវិភង្គ ។

# សម្មប្បធានវិភង្គោ

(៦១១) ចត្តារោ សម្មប្បធានា ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

(៦១២) កថញ្ច ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ អនុប្បន្នា បាបកា អកុសលា ធម្មា ។

# សម្មប្បធានវិភង្គ

(៦១១) សម្មប្បធាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចំរើន ពេញលេញ ១ ។

(៦១២) ចុះភិក្ខុញុំាងឆន្ទៈ ឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង តើដូចម្តេច ។

តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ អនុប្បន្នា បាបកា អកុសលា ធម្មា ។ ឥតិ ឥមេសំ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

(២១៣) ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ។ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិនិព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

(២១៤) វាយមតីតិ តត្ថ កតមោ វាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ អយំ វុច្ចតិ វាយាមោ ។ ឥមិនា វាយាមេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

អកុសលមូល ៣ គឺ លោភៈ ទោសៈ មោហៈ និងពួកកិលេស ដែលឋិតនៅជាមួយនិងអកុសលមូលនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសនោះ កាយកម្ម វចីកម្ម មនោ-កម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា អកុសលធម៌ ដ៏លាមក ដែលមិនទាន់កើតឡើង ។ ភិក្ខុ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងអកុសលធម៌ ដ៏លាមក ទាំងនេះ ដែលមិនទាន់កើត មិនឲ្យកើតឡើង ដោយប្រការដូច្នេះ ។

[៦១៣] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ សេចក្ដីប្រា-ថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុញុំាងឆន្ទៈនេះ ឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចំរើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុំាងឆន្ទៈឲ្យកើត ។

[៦១៤] ត្រង់ពាក្យថា សង្វាត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសង្វាត តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ ណា នេះហៅថា សេចក្ដីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប ក្បៀកកើយ ប្រជិតប្រជី ប្រកបព្រមដោយសេចក្ដីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[២១៥] វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

[២១៦] ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។បេ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

[២១៧] បទហតីតិ តត្ថ កតមំ បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។បេ។ សមន្នាគតោ តេន វុច្ចតិ បទហតីតិ ។

[ ២១៥ ] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[ ២១៦ ] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[ ២១៧ ] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ ណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[២១៨] កតមញ្ច ភិក្ខុ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ ឧប្បន្នា បាបកា អកុសលា ធម្មា ។ តីណិ អកុសលមូលានិ លោភោ ទោសោ មោហោ តទេកដ្ឋា ច កិលេសា តំសម្បយុត្តោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ ឧប្បន្នា បាបកា អកុសលា ធម្មា ។ ឥតិ ឥមេសំ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២១៩] ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ។ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិនិព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

[២១៨] ចុះភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្តេច ។ អកុសលមូល ៣ គឺ លោភៈ ទោសៈ មោហៈ និងពួកកិលេស ដែលឋិតនៅជាមួយនឹងអកុសលមូលនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេសនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយអកុសលមូលនោះ ធម៌ទាំងនេះ ហៅថា ពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។ ភិក្ខុញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមកទាំងនេះ ដែលកើតឡើងហើយ ដោយប្រការដូច្នេះ ។

[២១៩] ត្រង់ពាក្យថា ញ៉ាំងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាបទទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុញ៉ាំងឆន្ទៈនេះ ឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចំរើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញ៉ាំងឆន្ទៈឲ្យកើត ។

[២២០] វាយមតីតិ តត្ថ កតមោ វាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ អយំ វុច្ចតិ វាយាមោ ឥមិនា វាយាមេន ឧបេតោ ហោតិ ។បេ។ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

[២២១] វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

[២២២] ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។បេ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

[៦២០] ត្រង់ពាក្យថា សង្វាត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសង្វាត តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ ណា នេះហៅថា សេចក្ដីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង ។បេ។ ប្រកបព្រម ដោយសេចក្ដីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[៦២១] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ការព្យាយាម តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[៦២២] ត្រង់ពាក្យ ផ្គងចិត្ត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនោះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[៦៦៣] បធានានីតិ តត្ថ កតមំ បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ បធានានីតិ ។

[៦៦៤] កថញ្ច ភិក្ខុ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ អនុប្បន្នា កុសលា ធម្មា ។ តីណិ កុសលមូលានិ អលោភោ អទោសោ អមោហោ តំសម្បយុត្តោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ អនុប្បន្នា កុសលា ធម្មា ។ ឥតិ ឥមេសំ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[៦៦៥] ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ បេ ។ បទហតីតិ តត្ថ កតមំ បធានំ ។

(៤៤៣) ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

(៤៤៤) ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាមផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង តើដូចម្តេច ។ កុសលមូល ៣ គឺ អលោភៈ អទោសៈ អមោហៈ និងវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាមផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ទាំងនេះ ដែលមិនទាន់កើត ឲ្យកើតឡើង ដោយប្រការដូច្នេះ ។

(៤៤៥) ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច ។

យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។ បេ ។ សមន្នាគតោ តេន វុច្ចតិ បទហតីតិ ។

(២២៦) កថញ្ច ភិក្ខុ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្ថ កតមេ ឧប្បន្នា កុសលា ធម្មា ។ តីណិ កុសលមូលានិ អលោភោ អទោសោ អមោហោ តំសម្បយុត្តោ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ តំសមុដ្ឋានំ កាយកម្មំ វចីកម្មំ មនោកម្មំ ឥមេ វុច្ចន្តិ ឧប្បន្នា កុសលា ធម្មា ។ ឥតិ ឥមេសំ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ការប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

[៦៦៦] ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្កាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចំរើន ពេញលេញ តើដូចម្តេច ។ បណ្តាធម៌ទាំងនោះ ពួកកុសលធម៌ ដែលកើតឡើងហើយ តើដូចម្តេច ។ កុសលមូល ៣ គឺ អលោភៈ អទោសៈ អមោហៈ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងដោយខន្ធនោះ ធម៌ទាំងនេះហៅថា ពួកកុសលធម៌ ដែលកើតឡើងហើយ ។ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្កាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងកុសលធម៌ទាំងនេះ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចំរើន ពេញលេញ ដោយប្រការដូច្នេះ ។

(២២៧) ឋិតិយាតិ យា ឋិតិ សោ អសម្មោសោ យោ អសម្មោសោ សោ ភិយ្យោភាវោ យោ ភិយ្យោភាវោ តំ វេបុល្លំ យំ វេបុល្លំ សា ភាវនា យា ភាវនា សា បារិបូរី ។

(២២៨) ឆន្ទំ ជនេតីតិ ។បេ។ វាយមតីតិ ។បេ។ វីរិយំ អារភតីតិ ។បេ។ ចិត្តំ បគ្គណ្ហាតីតិ ។បេ។ បទហតីតិ តត្ថ កតមំ បធានំ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ ឥទំ វុច្ចតិ បធានំ ឥមិនា បធានេន ឧបេតោ ហោតិ ។បេ។ សមន្នាគតោ តេន វុច្ចតិ បទហតីតិ ។

## សុត្តន្តភាជនីយំ ។

(២២៩) ចត្តារោ សម្មប្បធានា ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ

[៤២៧] ពាក្យថា ឲ្យឋិតនៅ គឺការឋិតនៅ ណា នោះឈ្មោះថាសេចក្តីមិនវិនាស ឯសេចក្តីមិនវិនាស ណា នោះឈ្មោះថា ការរឹងរឹតតែដុះដាលឡើង ការរឹងរឹតតែដុះដាលឡើង ណា នោះឈ្មោះថាធំទូលាយ ការធំទូលាយ ណា នោះឈ្មោះថា ការចំរើន ការចំរើន ណា នោះឈ្មោះថា ការពេញលេញ ។

[៤២៨] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង សេចក្តីថា បណ្តាពាក្យទាំងនោះ ការប្រឹងប្រែង តើដូចម្តេច សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ ណា នេះហៅថា ប្រឹងប្រែង ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយការប្រឹងប្រែងនេះ ព្រោះហេតុនោះ ទើបពោលថា ប្រឹងប្រែង ។

ចប់ សុត្តន្តភាជនីយ ។

[៤២៩] សម្មប្បធាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត

វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្ប-
ន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ
វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ
ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោ-
សាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូ-
រិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ
បគ្គណ្ហាតិ បទហតិ ។

(២៣០) កថញ្ច ភិក្ខុ អនុប្បន្នានំ បាប-
កានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ
ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ
បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ
ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ
បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ
កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហ-
រតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ អនុ-
ប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បា-
ទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ
បគ្គណ្ហាតិ បទហតិ ។

ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចំរើន ពេញលេញ ១ ។

(២៣០) ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេស) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ។

[២៣១] ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិនិព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

[២៣២] វាយមតីតិ តត្ថ កតមោ វាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ឋិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ វីរិយពលំ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ វាយាមោ ឥមិនា វាយាមេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

[២៣១] ត្រង់ពាក្យថា ញ៉ាំងឆន្ទៈឲ្យកើត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ សេចក្ដីប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុញ៉ាំងឆន្ទៈនេះ ឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចំរើន ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញ៉ាំងឆន្ទៈឲ្យកើត ។

[២៣២] ត្រង់ពាក្យថា សង្វាត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សេចក្ដីសង្វាត តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង ខ្ជាប់ខ្ជួនមិនបន្ធូរបន្ថយ មិនដាក់ចោលនូវសេចក្ដីប្រាថ្នា មិនទម្លាក់ធុរៈចេញ ផ្គងទុកនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សេចក្ដីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប កៀកកើយ ប្រជិតប្រជី ប្រកបព្រម ដោយសេចក្ដីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

( ២៣៣ ) វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

( ២៣៤ ) ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

( ២៣៥ ) បទហតីតិ តត្ថ កតមំ សម្មប្បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

[ ២៣៣ ] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ ការប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

[ ២៣៤ ] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ភិក្ខុ ផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[ ២៣៥ ] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេសក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[២៣៦] កតមញ្ច ភិក្ខុ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[២៣៧] ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ បេ ។ បទហតីតិ តត្ថ កតមំ សម្មប្បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

( ៦៣៦ ) ចុះភិក្ខុ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ បំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ។

( ៦៣៧ ) ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សម្មប្បធាន តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

## សម្មប្បធានវិភង្គេ អភិធម្មភាជនីយំ

(២៣៨) កថញ្ច ភិក្ខុ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

(២៣៩) ឆន្ទំ ជនេតីតិ ។ បេ ។ វាយមតីតិ ។ បេ ។ វីរិយំ អារភតីតិ ។ បេ ។ ចិត្តំ បគ្គណ្ហាតីតិ ។ ប ។ បទហតីតិ តត្ថ កតមំ សម្មប្បធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

( ២៣៨ ) ចុះភិក្ខុញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកិលេសវដ្តៈ ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ។

( ២៣៩ ) ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត ។ បេ ។ ត្រង់ពាក្យថា សង្វាត ។ បេ ។ ត្រង់ពាក្យថា ប្រារព្ធព្យាយាម ។ បេ ។ ត្រង់ពាក្យថា ផ្គងចិត្ត ។ បេ ។ ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្តីថា បណ្តាពាក្យទាំងនោះ សម្មប្បធាន តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

[៦៦០] កតមញ្ច ភិក្ខុ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។

[៦៦១] ឋិតិយាតិ យា ឋិតិ សោ អសម្មោសោ យោ អសម្មោសោ សោ ភិយ្យោភាវោ យោ ភិយ្យោភាវោ តំ វេបុល្លំ យំ វេបុល្លំ សា ភាវនា យា ភាវនា សា បារិបូរិ ។

[២៦០] ចុះភិក្ខុ ញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចំរើន ពេញលេញ តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ដើម្បីលះបង់នូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ញ៉ាំងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ ចំរើន ពេញលេញ ។

[២៦១] ត្រង់ពាក្យថា ឲ្យឋិតនៅ គឺការឋិតនៅ ណា នោះឈ្មោះថា សេចក្តីមិនវិនាស ឯសេចក្តីមិនវិនាស ណា នោះឈ្មោះថា ការរឹងរឹតតែដុះដាលឡើង ការរឹងរឹតតែដុះដាលឡើង ណា នោះឈ្មោះថា ធំទូលាយ ការធំទូលាយ ណា នោះឈ្មោះថា ការចំរើន ការចំរើន ណា នោះឈ្មោះថា ការពេញលេញ ។

(២៤២) ឆន្ទំ ជនេតីតិ តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ឥមំ ឆន្ទំ ជនេតិ សញ្ជនេតិ ឧដ្ឋាបេតិ សមុដ្ឋាបេតិ និព្វត្តេតិ អភិនិព្វត្តេតិ តេន វុច្ចតិ ឆន្ទំ ជនេតីតិ ។

(២៤៣) វាយមតីតិ តត្ថ កតមោ វាយាមោ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ អយំ វុច្ចតិ វាយាមោ ឥមិនា វាយាមេន ឧបេតោ ហោតិ ។បេ។ សមន្នាគតោ តេន វុច្ចតិ វាយមតីតិ ។

(២៤៤) វីរិយំ អារភតីតិ តត្ថ កតមំ វីរិយំ ។ យោ ចេតសិកោ វីរិយារម្ភោ ។បេ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ វីរិយំ ឥមំ វីរិយំ អារភតិ សមារភតិ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ វីរិយំ អារភតីតិ ។

[៤៤២] ត្រង់ពាក្យថា ញុំាងឆន្ទៈឲ្យកើត មានសេចក្តីថា បណ្តាពាក្យទាំងនោះ ឆន្ទៈ តើដូចម្តេច ។ សេចក្តីប្រាថ្នា ភាពនៃបុគ្គលមានសេចក្តីប្រាថ្នា ភាពនៃបុគ្គលអ្នកប្រាថ្នាដើម្បីធ្វើ សេចក្តីប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ភិក្ខុ ញុំាងឆន្ទៈនេះឲ្យកើត ឲ្យលូតលាស់ ឲ្យដុះដាល ឲ្យតាំងឡើង ឲ្យចំរើនឡើង ឲ្យកើតឡើង ព្រោះហេតុនោះ ទើបពោលថា ញុំាងឆន្ទៈឲ្យកើត ។

[៤៤៣] ត្រង់ពាក្យថា សង្វាត មានសេចក្តីថា បណ្តាពាក្យទាំងនោះ សេចក្តីសង្វាត តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ គឺវិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សេចក្តីសង្វាត ភិក្ខុជាអ្នកព្រមព្រៀង ។ បេ ។ ប្រកបព្រម ដោយសេចក្តីសង្វាតនេះ ព្រោះហេតុនោះ ទើបពោលថា សង្វាត ។

[៤៤៤] ត្រង់ពាក្យថា ប្រារព្ធព្យាយាម មានសេចក្តីថា បណ្តាពាក្យទាំងនោះ ការព្យាយាម តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។ បេ ។ សម្មាវាយាមៈ វិរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា ការព្យាយាម ភិក្ខុប្រារព្ធ កាន់យកត្រូវ គប់រក អប់រំ ធ្វើឲ្យច្រើន នូវការព្យាយាមនេះ ព្រោះហេតុនោះ ទើបពោលថា ប្រារព្ធព្យាយាម ។

(២៤៥) ចិត្តំ បគ្គណ្ហាតីតិ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ឥមំ ចិត្តំ បគ្គណ្ហាតិ សម្បគ្គណ្ហាតិ ឧបត្ថម្ភេតិ បច្ចុបត្ថម្ភេតិ តេន វុច្ចតិ ចិត្តំ បគ្គណ្ហាតីតិ ។

(២៤៦) បទហតីតិ តត្ថ កតមំ សម្មប្ប-ធានំ ។ យោ ចេតសិកោ វីរិយារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ មគ្គង្គំ មគ្គបរិយា-បន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវសេសា ធម្មា សម្មប្បធានសម្បយុត្តា ។

(២៤៧) តត្ថ កតមំ សម្មប្បធានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ យោ តស្មឹ សមយេ ចេតសិកោ វីរិ-យារម្ភោ ។ បេ ។ សម្មាវាយាមោ វីរិយសម្ពោជ្ឈង្គោ

[២៨៥] ត្រង់ពាក្យថា ផ្គងចិត្ត មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ។បេ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះណា នេះហៅថា ចិត្ត ភិក្ខុផ្គង តម្រង់ ជ្រោមជ្រែង ទប់ទល់ទុក នូវចិត្តនេះ ព្រោះហេតុនោះ ទើបពោលថា ផ្គងចិត្ត ។

[២៨៦] ត្រង់ពាក្យថា ប្រឹងប្រែង មានសេចក្ដីថា បណ្ដាពាក្យទាំងនោះ សម្មប្បធាន តើដូចម្ដេច ។ សេចក្ដីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយសម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថា សម្មប្បធាន ពួកធម៌ដ៏សេស ដែលប្រកបដោយសម្មប្បធាន (ក៏ឈ្មោះថា សម្មប្បធានដែរ) ។

[២៨៧] បណ្ដាពាក្យទាំងនោះ សម្មប្បធាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ បំរើននូវលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្ដៈ) ដើម្បីលះនូវទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ក្នុងសម័យនោះ សេចក្ដីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ។បេ។ សម្មាវាយាមៈ វីរិយៈ

មគ្គង្គំ មគ្គបរិយាបន្នំ ឥទំ វុច្ចតិ សម្មប្បធានំ អវ-សេសា ធម្មា សម្មប្បធានសម្បយុត្តា ។

## អភិធម្មភាជនីយំ ។

(៤៤៨) ចត្តារោ សម្មប្បធានា ឥធ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បា-ទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុស-លានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្ប-ន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោ-សាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ចតុន្នំ សម្មប្បធានានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។បេ។ កតិ សរណា កតិ អរណា ។

សម្ពោជ្ឈង្គ ជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គ ណា នេះហៅថាសម្មប្បធាន ពួកធម៌ដ៏សេស ក៏ឈ្មោះថា ប្រកបដោយសម្មប្បធាន ។

ចប់ អភិធម្មភាជនីយ ។

[ ៦៤៨ ] សម្មប្បធាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើត សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ បំរើន ពេញលេញ ។ បណ្តាសម្មប្បធានទាំង ៤ សម្មប្បធាន ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។ បេ ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

[ ២៤៩ ] កុសលាយេវ សិយា សុខាយ វេ-
ទនាយ សម្បយុត្តា សិយា អទុក្ខមសុខាយ វេទ-
នាយ សម្បយុត្តា វិបាកធម្មធម្មា អនុបាទិន្នុបា-
ទានិយា អសង្កិលិដ្ឋសង្កិលេសិកា សិយា
សវិតក្កសវិចារា សិយា អវិតក្កវិចារមត្តា សិយា
អវិតក្កាវិចារា សិយា បីតិសហគតា សិយា
សុខសហគតា សិយា ឧបេក្ខាសហគតា នេវ
ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្ស-
នេន ន ភាវនាយ បហាតព្វហេតុកា អបចយគា-
មិនោ សេក្ខា អប្បមាណា អប្បមាណារម្មណា
បណីតា សម្មត្តនិយតា ន មគ្គារម្មណា មគ្គហេ-
តុកា សិយា មគ្គាធិបតិនោ សិយា ន វត្តព្វា
មគ្គាធិបតិនោតិ សិយា ឧប្បន្នា សិយា អនុប្បន្នា
ន វត្តព្វា ឧប្បាទិនោតិ សិយា អតីតា សិយា
អនាគតា សិយា បច្ចុប្បន្នា ន វត្តព្វា អតីតារម្ម-
ណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ
សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្ត-
ពហិទ្ធា ពហិទ្ធារម្មណា អនិទស្សនាប្បដិឃា ។

[ ៦៤៩ ] សម្មប្បធាន ៤ ជាកុសលតែមួយយ៉ាង ប្រកបដោយសុខវេទនាក៏មាន ប្រកបដោយអទុក្ខមសុខវេទនា តែមានវិបាកធម៌ជាប្រក្រតី ដែលកិលេសមានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទាន មិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មងក៏មាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈក៏មាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈក៏មាន មិនមានវិតក្កៈ មិនមានវិចារៈក៏មាន ប្រកបដោយបីតិក៏មាន ប្រកបដោយសុខក៏មាន ប្រកបដោយឧបេក្ខា តែមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះ ដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា ជាគ្រឿងដល់នូវការមិនសន្សំ (នូវកិលេសវដ្តៈ) ជារបស់សេក្ខបុគ្គល មានប្រមាណមិនបាន មានអារម្មណ៍ប្រមាណមិនបាន ដ៏ឧត្តម មានសភាពត្រូវនិងទៀង មិនមានមគ្គជាអារម្មណ៍ មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអធិបតីក៏មាន ដែលកើតឡើងហើយក៏មាន មិនទាន់កើតហើយក៏មាន មិនគួរពោលថា បម្រុងនឹងកើតទេ ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្ន តែមិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍អនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងនិងខាងក្រៅ មានអារម្មណ៍ជាខាងក្រៅ មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ក៏មាន ។

[ ២៥០ ] ន ហេតូ សហេតុកា ហេតុសម្បយុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិបិ សាសវា ចេវ នោ ច អាសវាតិបិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។ បេ ។ នោ គន្ថា ។ បេ ។ នោ ឱឃា ។ បេ ។ នោ យោគា ។ បេ ។ នោ នីវរណា ។ បេ ។ នោ បរាមាសា ។ បេ ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា

[៤៩០] សម្មប្បធាន ៤ មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ មិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ សម្មប្បធាន ៤ ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ មិនមានរូប ជាលោកុត្តរ គួរដឹងដោយវិញ្ញាណណាមួយ មិនគួរដឹងដោយវិញ្ញាណណាមួយ ។ សម្មប្បធាន ៤ មិនមែនជាអាសវៈ មិនមានអាសវៈ ប្រាសចាកអាសវៈ មិនគួរពោលថា អាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈផងទេ មិនគួរពោលថា អាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ គឺជាធម៌ ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈ ។ សម្មប្បធាន ៤ មិនមែនសញ្ញោជនៈ ។ បេ ។ មិនមែនគន្ថៈ ។ បេ ។ មិនមែន ឱឃៈ ។ បេ ។ មិនមែនយោគៈ ។ បេ ។ មិនមែននីវរណៈ ។ បេ ។ មិនមែនបរាមាសៈ ។ បេ ។ ប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត

ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋសមុដ្ឋានានុបរិវត្តិនោ ពាហិរា នុបាទា អនុបាទិន្នា ។ នុបាទានា ។ បេ ។ នោ កិលេសា ។ បេ ។ ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ន ភាវនាយ បហាតព្វហេតុកា សិយា សវិតក្កា សិយា អវិតក្កា សិយា សវិចារា សិយា អវិចារា សិយា សប្បីតិកា សិយា អប្បីតិកា សិយា បីតិសហគតា សិយា ន បីតិសហគតា សិយា សុខសហគតា សិយា ន សុខសហគតា សិយា ឧបេក្ខាសហគតា សិយា ន ឧបេក្ខាសហគតា ន កាមាវចរា ន រូបាវចរា ន អរូបាវចរា អបរិយាបន្នា និយ្យានិកា និយតា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

សម្មប្បធានវិភង្គោ សមត្តោ ។

ប្រឡំដោយចិត្ត តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅ តាមចិត្ត ប្រឡំ ទាំងតាំងឡើងដោយចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា ដែលកិលេសមានតណ្ហាជាដើម មិន កាន់យក ។ សម្មប្បធាន ៤ មិនមែនឧបាទាន ។ បេ ។ មិនមែន កិលេស ។ បេ ។ មិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ មានហេតុមិនគួរលះដោយភាវនា ប្រកបដោយវិតក្កៈក៏មាន មិនមានវិតក្កៈក៏មាន ប្រកបដោយវិចារៈក៏ មាន មិនមានវិចារៈក៏មាន ប្រកបដោយបីតិក៏មាន មិនមានបីតិក៏មាន ប្រឡំដោយបីតិក៏មាន មិនប្រឡំដោយបីតិក៏មាន ប្រឡំដោយសុខក៏ មាន មិនប្រឡំដោយសុខក៏មាន ប្រឡំដោយឧបេក្ខាក៏មាន មិន ប្រឡំដោយឧបេក្ខា តែមិនមែនកាមាវចរ មិនមែនរូបាវចរ មិនមែន អរូបាវចរ ជាអបរិយាបន្នៈ ជានិយ្យានិកៈ ជានិយតៈ ជាអនុត្តរៈ ជាអរណៈ ក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ សម្មប្បធានវិភង្គ ។

# ឥទ្ធិបាទវិភង្គោ

(២៨១) ចត្តារោ ឥទ្ធិបាទា ឥធ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។

(២៨២) កថញ្ច ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ ឆន្ទញ្ចេ ភិក្ខុ អធិបតឹ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ អយំ វុច្ចតិ ឆន្ទសមាធិ ។ សោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ

# ឥទ្ធិបាទវិភង្គ

[៤៥១] ឥទ្ធិបាទ ៤ គឺ ភិក្ខុក្នុងសាសនានេះ ចំរើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ១ ចំរើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ១ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។

[៤៥២] ចុះភិក្ខុ ចំរើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ តើដូចម្តេច ។ បើភិក្ខុ ធ្វើឆន្ទៈ ឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា ឆន្ទសមាធិ ។ ភិក្ខុនោះ ញុំាងឆន្ទៈឲ្យកើត សង្កាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើត មិនឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើត សង្កាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីលះនូវពួកអកុសលធម៌ដ៏លាមក ដែលកើតហើយ ញុំាងឆន្ទៈឲ្យកើត សង្កាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញុំាងពួកកុសលធម៌ ដែលមិនទាន់កើត ឲ្យកើតឡើង

បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥមេ វុច្ចន្តិ បធានសង្ខារា ។ ឥតិ អយញ្ច ឆន្ទសមាធិ ឥមេ ច បធានសង្ខារា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា ឆន្ទសមាធិប្បធានសង្ខារោត្វេវ សំខ្យំ គច្ឆតិ ។

(២៥៣) តត្ថ កតមោ ឆន្ទោ ។ យោ ឆន្ទោ ឆន្ទិកតា កត្តុកម្យតា កុសលោ ធម្មច្ឆន្ទោ អយំ វុច្ចតិ ឆន្ទោ ។ តត្ថ កតមោ សមាធិ ។ យា ចិត្តស្ស ឋិតិ សណ្ឋិតិ អវដ្ឋិតិ អវិសាហារោ អវិក្ខេបោ អវិសាហដមានសតា សមថោ សមាធិន្ទ្រិយំ សមាធិពលំ សម្មាសមាធិ អយំ វុច្ចតិ សមាធិ ។ តត្ថ កតមោ បធានសង្ខារោ ។ យោ ចេតសិកោ វីរិយារម្ភោ និក្កមោ បរក្កមោ ឧយ្យាមោ វាយាមោ ឧស្សាហោ ឧស្សោឡ្ហី ថាមោ ឋិតិ អសិថិលបរក្កមតា អនិក្ខិត្តច្ឆន្ទតា អនិក្ខិត្តធុរតា ធុរសម្បគ្គាហោ វីរិយំ វីរិយិន្ទ្រិយំ

ញ៉ាំងឆន្ទៈឲ្យកើត សង្កាត ប្រារព្ធព្យាយាម ផ្គងចិត្ត ប្រឹងប្រែង ដើម្បីញ៉ាំងពួកកុសលធម៌ ដែលកើតហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹងរឹតតែដុះដាល ធំទូលាយ បំរើន ពេញលេញ ធម៌ទាំងនេះ ហៅថា បធានសង្ខារ ។ ឆន្ទសមាធិនេះផង បធានសង្ខារ នេះផង ដល់នូវការរាប់ថា ឆន្ទសមាធិ និងបធានសង្ខារ ព្រោះប្រមូលរួបរួម នូវធម៌នោះគង់ទីជាមួយគ្នា ដោយប្រការដូច្នេះ ។

[៤៩៣] បណ្ដាធម៌ទាំងនោះ ឆន្ទៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នា ភាពនៃបុគ្គលមានសេចក្ដីប្រាថ្នា ភាពនៃបុគ្គលប្រាថ្នាដើម្បីធ្វើ ការប្រាថ្នាធម៌ជាកុសល ណា នេះហៅថា ឆន្ទៈ ។ បណ្ដាធម៌ទាំងនោះ សមាធិ តើដូចម្ដេច ។ ការតាំងនៅ ការឈ្ឋប់ខ្ជួន ការឋិតនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ សមាធិន្ទ្រិយ សមាធិពលៈ សម្មាសមាធិ ណា នៃចិត្ត នេះហៅថា សមាធិ ។ បណ្ដាធម៌ទាំងនោះ បធានសង្ខារ តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត ការឱហាត សង្កាត ខឹតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្មីឃ្មាត ខ្នះខ្នែង សេចក្ដីសង្កាតមិនបន្ធូរបន្ថយ មិនដាក់ចោលនូវសេចក្ដីប្រាថ្នា មិនទម្លាក់ធុរៈចេញ ផ្គងទុកនូវធុរៈ វីរិយៈ វីរិយិន្ទ្រិយ

វីរិយពលំ សម្មាវាយាមោ អយំ វុច្ចតិ បធានសង្ខារោ ។ ឥតិ ឥមិនា ច ឆន្ទេន ឥមិនា ច សមាធិនា ឥមិនា ច បធានសង្ខារេន ឧបេតោ ហោតិ សមុបេតោ ឧបាគតោ សមុបាគតោ ឧបបន្នោ សមុបបន្នោ សមន្នាគតោ តេន វុច្ចតិ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតោតិ ។

(២៨៧) ឥទ្ធីតិ យា តេសំ ធម្មានំ ឥទ្ធិ សមិទ្ធិ ឥជ្ឈនា សមិជ្ឈនា លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។ ឥទ្ធិបាទោតិ តថាភូតស្ស វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។ ឥទ្ធិបាទំ ភាវេតីតិ តេ ធម្មេ អាសេវតិ ភាវេតិ ពហុលីករោតិ តេន វុច្ចតិ ឥទ្ធិបាទំ ភាវេតីតិ ។

(២៨៨) កតមញ្ច ភិក្ខុ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ វីរិយញ្ចេ ភិក្ខុ អធិបតឹ ករិត្វា លភតិ សមាធឹ លភតិ ចិត្តស្ស ឯកគ្គតំ អយំ វុច្ចតិ វីរិយសមាធិ ។

វីរិយពលៈ សម្មាវាយាមៈ ណា នេះហៅថា បធានសង្ខារ ។ ភិក្ខុ ជាអ្នកព្រមព្រៀង មូលមិត ចូលទៅជិត អែបនែប កៀកកើយ ប្រ-ដិតប្រដី ប្រកបព្រម ដោយឆន្ទៈនេះផង ដោយសមាធិនេះផង ដោយបធានសង្ខារនេះផង ព្រោះហេតុនោះ ទើបពោលថា ប្រកបដោយឆន្ទ-សមាធិ និងបធានសង្ខារ ដោយប្រការដូច្នេះ ។

[ ៦៥៨ ] ពាក្យថា ឥទ្ធិ បានដល់ ការសម្រេច ការសម្រេចព្រម អាការសម្រេច អាការសម្រេចព្រម ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ កិរិយាធ្វើឲ្យជាក់ច្បាស់ ការបានគ្រប់គ្រាន់ នូវធម៌ទាំងឡាយនោះ ។ ពាក្យថា ឥទ្ធិបាទ គឺ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ របស់បុគ្គលមានសភាពដូច្នោះ ។ ពាក្យថា ចំរើននូវឥទ្ធិបាទ គឺ ភិក្ខុគប់រក អប់រំ ធ្វើឲ្យច្រើន នូវធម៌ទាំងនោះ ព្រោះហេតុនោះ ទើបពោលថា ចំរើននូវឥទ្ធិបាទ ។

[៦៥៩] ចុះភិក្ខុចំរើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធាន-សង្ខារ តើដូចម្តេច ។ បើភិក្ខុ ធ្វើវីរិយៈឲ្យជាអធិបតី រមែងបាននូវសមាធិ បាននូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ នេះហៅថា វីរិយសមាធិ ។

សោ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ អកុសលានំ ធម្មានំ បហានាយ ។បេ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ។បេ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឥមេ វុច្ចន្តិ បធានសង្ខារា ។ ឥតិ អយញ្ច វីរិយសមាធិ ឥមេ ច បធានសង្ខារា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា វីរិយសមាធិប្បធានសង្ខារោត្វេវ សង្ខ្យំ គច្ឆតិ ។

[៤៣០] ត្រង់ពាក្យថា ចតុត្ថៈ គឺជាគំរប់ ៤ ដោយលំដាប់នៃការរាប់ បុគ្គលចូលកាន់ឈានទី ៤ នេះ ព្រោះហេតុនោះ ទើបឈ្មោះថា ចតុត្ថៈ ។

[៤៣១] ត្រង់ពាក្យថា ឈាន គឺ ឧបេក្ខា សតិ ឯកគ្គតានៃចិត្ត ។

(៤៣២) ឧបសម្បជ្ជាតិ យោ ចតុត្ថស្ស ឈានស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

(៤៣៣) វិហរតីតិ ឥរិយតិ ។បេ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

(៤៣៤) សព្វសោ រូបសញ្ញានំ សមតិក្កមាតិ តត្ថ កតមា រូបសញ្ញាយោ ។ យា រូបាវចរសមាបត្តឹ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា សញ្ញា សញ្ជាននា សញ្ជានិតត្តំ ឥមា វុច្ចន្តិ រូបសញ្ញាយោ ឥមា រូបសញ្ញាយោ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ រូបសញ្ញានំ សមតិក្កមាតិ ។

(៤៣៥) បដិឃសញ្ញានំ អត្ថង្គមាតិ តត្ថ កតមា បដិឃសញ្ញាយោ ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ឥមា វុច្ចន្តិ

[៤៣២] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវចតុត្ថជ្ឈាន ។

[៤៣៣] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។ បេ ។ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៤៣៤] ត្រង់ពាក្យថា ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ សេចក្តីថា បណ្តាធម៌ទាំងនោះ រូបសញ្ញា តើដូចម្តេច ។ ការសំគាល់ អាការសំគាល់ ភាពនៃការសំគាល់ ណា របស់បុគ្គលអ្នកចូលកាន់រូបសមាបត្តិក្តី របស់បុគ្គលអ្នកប្រកប (ដោយរូបសមាបត្តិ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយរូបាវចរសមាបត្តិ) ក្តី នេះហៅថា រូបសញ្ញា បុគ្គល កន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវរូបសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងរូបសញ្ញា ដោយសព្វគ្រប់ ។

[៤៣៥] ត្រង់ពាក្យថា ព្រោះវិនាសទៅនៃបដិឃសញ្ញាទាំងឡាយ សេចក្តីថា បណ្តាធម៌ទាំងនោះ បដិឃសញ្ញា តើដូចម្តេច ។ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា នេះហៅថា

បដិឃសញ្ញាយោ ឥមា បដិឃសញ្ញាយោ សន្តា ហោន្តិ សមិតា វូបសន្តា អត្ថង្គតា អព្ភត្ថង្គតា អប្បិតា ព្យប្បិតា សោសិតា វិសោសិតា ព្យន្តីកតា តេន វុច្ចតិ បដិឃសញ្ញានំ អត្ថង្គមាតិ ។

(៤៣៦) នានត្តសញ្ញានំ អមនសិការាតិ តត្ថ កតមា នានត្តសញ្ញាយោ ។ យា អសមាបន្នស្ស មនោធាតុសមង្គិស្ស វា មនោវិញ្ញាណធាតុសមង្គិស្ស វា សញ្ញា សញ្ជាននា សញ្ជានិតត្តំ ឥមា វុច្ចន្តិ នានត្តសញ្ញាយោ ឥមា នានត្តសញ្ញាយោ ន មនសិការោតិ តេន វុច្ចតិ នានត្តសញ្ញានំ អមនសិការាតិ ។

(៤៣៧) អនន្តោ អាកាសោតិ តត្ថ កតមោ អាកាសោ ។ យោ អាកាសោ អាកាសគតំ អឃំ អឃគតំ វិវរោ វិវរគតំ អសម្ផុដ្ឋំ ចតូហិ មហាភូតេហិ អយំ វុច្ចតិ អាកាសោ តស្មឹ អាកាសេ ចិត្តំ ឋបេតិ សណ្ឋបេតិ អនន្តំ ផរតិ តេន វុច្ចតិ អនន្តោ អាកាសោតិ ។

បដិឃសញ្ញា បដិឃសញ្ញាទាំងនេះ ជាធម៌ស្ងប់ម្ងាប់ រលត់ ខ្ចាត់ ចេញ វិនាស សាបសូន្យ ខូចខាត ហិនហោច រីង ស្ងួត ធ្វើឲ្យអស់ទៅ ព្រោះហេតុនោះ ទើបពោលថា ព្រោះវិនាសទៅនៃបដិ-ឃសញ្ញាទាំងឡាយ ។

[៤៣៦] ត្រង់ពាក្យថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា សេចក្តីថា បណ្តាធម៌ទាំងនោះ នានត្តសញ្ញា តើដូចម្តេច ។ ការសំគាល់ អាការសំគាល់ ភាពនៃការសំគាល់ ណា របស់បុគ្គលអ្នកមិនចូលកាន់ (រូបសមាបត្តិ) ជាអ្នកព្រមព្រៀងដោយមនោធាតុក្តី ព្រមព្រៀងដោយមនោវិញ្ញាណធាតុក្តី នេះហៅថា នានត្តសញ្ញា បុគ្គលមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ។

[៤៣៧] ត្រង់ពាក្យថា អាកាសមិនមានទីបំផុត សេចក្តីថា បណ្តាធម៌ទាំងនោះ អាកាស តើដូចម្តេច ។ កន្លែងណា ដែលមិនអាចក្ឃរកស់បាន អាកាស ទីឥតទើស ទីអាកាស ទីចន្លោះ វាល មិនប៉ះពាល់ដោយមហាភូតរូបទាំង ៤ នេះហៅថា អាកាស ភិក្ខុតំកល់ តាំងទុក នូវចិត្ត ក្នុងអាកាសនោះ ផ្សាយចិត្តទៅកាន់ទីដែលមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា អាកាសមិនមានទីបំផុត ។

[៥៣៨] អាកាសានញ្ចាយតនន្តិ អាកាសានញ្ចាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[៥៣៩] ឧបសម្បជ្ជាតិ យោ អាកាសានញ្ចាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៥៤០] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៥៤១] សព្វសោ អាកាសានញ្ចាយតនំ សមតិក្កមាតិ ឥមំ អាកាសានញ្ចាយតនំ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កមាតិ ។

[៥៤២] អនន្តំ វិញ្ញាណន្តិ តំយេវ អាកាសំ វិញ្ញាណេន ផុដ្ឋំ មនសិករោតិ អនន្តំ ផរតិ តេន វុច្ចតិ អនន្តំ វិញ្ញាណន្តិ ។

(៤៣៨) ត្រង់ពាក្យថា អាកាសានញ្ចាយតនៈ បានដល់ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់អាកាសានញ្ចាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយអាកាសានញ្ចាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយអាកាសានញ្ចាយតនជ្ឈាន) ក្តី ។

(៤៣៩) ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវអាកាសានញ្ចាយតនជ្ឈាន ។

(៤៤០) ត្រង់ពាក្យថា សម្រេចសរិយាបថ គឺ សម្រេច ។ បេ ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចសរិយាបថ ។

(៤៤១) ត្រង់ពាក្យថា ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង គឺកិរិយាជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវអាកាសានញ្ចាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។

(៤៤២) ត្រង់ពាក្យថា វិញ្ញាណ មិនមានទីបំផុត គឺ កិរិយា ធ្វើទុកក្នុងចិត្ត ចំពោះអាកាសនោះឯង ដែលពាល់ត្រូវដោយវិញ្ញាណ ផ្សាយទៅកាន់ទីមិនមានទីបំផុត ព្រោះហេតុនោះ ទើបពោលថា វិញ្ញាណ មិនមានទីបំផុត ។

(៤៤៣) វិញ្ញាណញ្ចាយតនន្តិ វិញ្ញាណញ្ចាយ-
តនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខ-
វិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

(៤៤៤) ឧបសម្បជ្ជាតិ យោ វិញ្ញាណញ្ចាយ-
តនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា
សច្ឆិកិរិយា ឧបសម្បទា ។

(៤៤៥) វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ
តេន វុច្ចតិ វិហរតីតិ ។

(៤៤៦) សព្វសោ វិញ្ញាណញ្ចាយតនំ សម-
តិក្កមាតិ ឥមំ វិញ្ញាណញ្ចាយតនំ អតិក្កន្តោ ហោតិ
វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ វិញ្ញា-
ណញ្ចាយតនំ សមតិក្កមាតិ ។

(៤៤៧) នត្ថិ កិញ្ចីតិ តំយេវ វិញ្ញាណំ អភា-
វេតិ វិភាវេតិ អន្តរធាបេតិ នត្ថិ កិញ្ចីតិ បស្សតិ
តេន វុច្ចតិ នត្ថិ កិញ្ចីតិ ។

(៥៥៣) ត្រង់ពាក្យថា វិញ្ញាណញ្ចាយតនៈ បានដល់ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់វិញ្ញាណញ្ចាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយវិញ្ញាណញ្ចាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយវិញ្ញាណញ្ចាយតនជ្ឈាន) ក្តី ។

(៥៥៤) ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវវិញ្ញាណញ្ចាយតនជ្ឈាន ។

(៥៥៥) ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺសម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

(៥៥៦) ត្រង់ពាក្យថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង គឺ ភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវវិញ្ញាណញ្ចាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ។

(៥៥៧) ត្រង់ពាក្យថា វត្ថុតិចតួចមិនមាន គឺ ភិក្ខុ ចំរើនទូទៅ ចំរើនវិសេស នូវវិញ្ញាណនោះឯង ធ្វើឲ្យបាត់វិញ្ញាណ រមែងឃើញថា វត្ថុតិចតួច មិនមាន ព្រោះហេតុនោះ ទើបពោលថា វត្ថុតិចតួច មិនមាន ។

[៦៦៨] អាកិញ្ចញ្ញាយតនន្តិ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[៦៦៩] ឧបសម្បជ្ជាតិ យោ អាកិញ្ចញ្ញាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[៦៧០] វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

[៦៧១] សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្មាតិ ឥមំ អាកិញ្ចញ្ញាយតនំ អតិក្កន្តោ ហោតិ វីតិក្កន្តោ សមតិក្កន្តោ តេន វុច្ចតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្មាតិ ។

[៦៧២] នេវសញ្ញានាសញ្ញីតិ តំយេវ អាកិញ្ចញ្ញាយតនំ សន្តតោ មនសិករោតិ សង្ខារាវសេសសមាបត្តឹ ភាវេតិ តេន វុច្ចតិ នេវសញ្ញានាសញ្ញីតិ ។

[៥៨៨] ត្រង់ពាក្យថា អាកិញ្ចញ្ញាយតនៈ បានដល់ពួកធម៌ គឺចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលកាន់អាកិញ្ចញ្ញាយតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប (ដោយអាកិញ្ចញ្ញាយតនជ្ឈាន) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន (ដោយអាកិញ្ចញ្ញាយតនជ្ឈាន) ក្តី ។

[៥៨៩] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវអាកិញ្ចញ្ញាយតនជ្ឈាន ។

[៥៩០] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ។បេ។ នៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

[៥៩១] ត្រង់ពាក្យថា ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង គឺ ភិក្ខុជាអ្នកកន្លង ប្រព្រឹត្តកន្លង ឈានកន្លង នូវអាកិញ្ចញ្ញាយតនជ្ឈាននេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ។

[៥៩២] ត្រង់ពាក្យថា នេវសញ្ញានាសញ្ញា គឺ ភិក្ខុធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនជ្ឈាននោះឯង ដោយល្អិត ចំរើននូវសមាបត្តិមានសង្ខារសល់នៅ ព្រោះហេតុនោះ ទើបពោលថា នេវសញ្ញានាសញ្ញា ។

[ ៥៨៣ ] នេវសញ្ញានាសញ្ញាយតនន្តិ នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស វា ឧបបន្នស្ស វា ទិដ្ឋធម្មសុខវិហារិស្ស វា ចិត្តចេតសិកា ធម្មា ។

[ ៥៨៤ ] ឧបសម្បជ្ជាតិ យោ នេវសញ្ញានាសញ្ញាយតនស្ស លាភោ បដិលាភោ បត្តិ សម្បត្តិ ផុសនា សច្ឆិកិរិយា ឧបសម្បទា ។

[ ៥៨៥ ] វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

## សុត្តន្តភាជនីយំ ។

[ ៥៨៦ ] ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

[ ៥៨៧ ] តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ

[ ៤៩៣ ] ត្រង់ពាក្យថា នេវសញ្ញានាសញ្ញាយតនៈ បានដល់ពួកធម៌ គឺចិត្តនិងចេតសិក របស់បុគ្គលអ្នកចូលកាន់នេវសញ្ញានាសញ្ញា-យតនជ្ឈានក្តី របស់បុគ្គលអ្នកប្រកប ( ដោយនេវសញ្ញានាសញ្ញាយតន-ជ្ឈាន ) ក្តី របស់បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន ( ដោយនេវសញ្ញានា-សញ្ញាយតនជ្ឈាន ) ក្តី ។

[ ៤៩៤ ] ត្រង់ពាក្យថា ចូល គឺ ការបាន ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យជាក់ច្បាស់ ការបំពេញ នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ។

[ ៤៩៥ ] ត្រង់ពាក្យថា សម្រេចឥរិយាបថ គឺ សម្រេច ប្រព្រឹត្តរក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាកនៅ ព្រោះហេតុនោះ ទើបពោលថា សម្រេចឥរិយាបថ ។

ចប់ សុត្តន្តភាជនីយ ។

[ ៤៩៦ ] ឈាន ៤ យ៉ាង គឺបឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៩៧ ] បណ្តាឈានទាំងនោះ បឋមជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូប-ភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ ( ជាអារម្មណ៍ ) ហើយសម្រាកនៅ ក្នុងសម័យនោះ

បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៥៥៨ ) តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៥៥៩ ) តត្ថ កតមំ តតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៥៦០ ) តត្ថ កតមំ ចតុត្ថំ ឈានំ ។

ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៥៥៨ ) បណ្តាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៥៥៩ ) បណ្តាឈានទាំងនោះ តតិយជ្ឈាន តើដូចម្តេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិ ។ បេ ។ ចូលកាន់តតិយជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៥៦០ ) បណ្តាឈានទាំងនោះ ចតុត្ថជ្ឈាន តើដូចម្តេច ។

ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៦១) ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៦២) ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ អវិតក្កំ វិចារមត្តំ វិវេកជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ចតុរង្គិកំ ឈានំ ហោតិ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់នូវសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៦១) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៦២) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិនិងសុខកើតអំពីសេចក្ដីស្ងាត់ មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៤ គឺ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៤៦៣ ) ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៤៦៤ ) ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ បីតិយា ច វិរាគា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៤៦៥ ) ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ សុខស្ស ច បហានា ។បេ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[៥៦៣] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៥៦៤] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៥៦៥] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

ឈានវិភង្គេ អភិធម្មភាជនីយំ

(៦៦៦) ឥធ ភិក្ខុ យស្មឹ សមយេ អរូបូបបត្តិយា មគ្គំ ភាវេតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៦៧) ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

(៦៦៨) តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

[ ៤៦៦ ] ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៦៧ ] ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

[ ៤៦៨ ] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៦៦៩ ) តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិតក្ក-វិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៦៧០ ) តត្ថ កតមំ តតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហា-នាយ បឋមាយ ភូមិយា បត្តិយា បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

( ៦៧១ ) តត្ថ កតមំ ចតុត្ថំ ឈានំ ។

[ ៤៦៩ ] បណ្ដាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ចិត្តេកគ្គតា នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧០ ] បណ្ដាឈានទាំងនោះ តតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះនឿយណាយចាកបីតិផង ។ បេ ។ ចូលកាន់តតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[ ៤៧១ ] បណ្ដាឈានទាំងនោះ ចតុត្ថជ្ឈាន តើដូចម្ដេច ។

ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៧២) ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៧៣) ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា

ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះលះសុខផង ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៤៧២ ) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

( ៤៧៣ ) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ( នូវកម្មកិលេស ) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ( លុះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ )

បត្តិយា(១) អវិតក្កំ វិចារមត្តំ វិវេកជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ចតុរង្គិកំ ឈានំ ហោតិ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ទុតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៧៤) ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិតក្កវិចារានំ វូបសមា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ តិវង្គិកំ ឈានំ ហោតិ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ តតិយំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៧៥) ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា បីតិយា ច វិរាគា ។ បេ ។ ចតុត្ថំ ឈានំ

---

១ ម. ឯត្តន្តរេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហីតិ ទិស្សន្តិ ។

ចូលកាន់ទុតិយជ្ឈាន មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានបីតិនិងសុខ កើតក្នុងវិវេក ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៤ គឺ វិចារៈ បីតិ សុខ ឯកគ្គតា ក៏កើតមាន នេះហៅថា ទុតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៧៤) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់តតិយជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា ក៏កើតមាន នេះហៅថា តតិយជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៧៥) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់ នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះនឿយណាយ ចាកបីតិផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន

ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៧៦) ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា សុខស្ស ច បហានា ។បេ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៧៧) ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

(៦៧៨) តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ផស្សោ

ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៧៦) ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៧៧) ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

(៤៧៨) បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ

ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បថវីកសិណំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៧៩) តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបូបបត្តិយា មគ្គំ ភាវេតិ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឧបសម្បជ្ជ វិហរតិ បថវីកសិណំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ រូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ។បេ។ តតិយំ ឈានំ ។បេ។ ចតុត្ថំ ឈានំ ។បេ។ បឋមំ ឈានំ ។បេ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ បថវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ

ក៏កើតមាន ។ បេ ។ អវិក្ខេបៈ (ការមិនរាយមាយ) ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់ បឋមជ្ឈាន ជាវិបាក មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាក នៅ ព្រោះភាពនៃកម្ម ជារូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៧៩) បណ្ដាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងរូបភព ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន មានបឋវីក-សិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះឈ្មោះថាជា កុសល ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន ជាវិបាក ព្រោះភាពនៃកម្មជារូបាវចរកុសល នោះឯង ដែលលោកធ្វើហើយ សន្សំហើយ មានបឋវីកសិណ (ជាអា-រម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ

ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។ បេ ។ ឥធ ភិក្ខុ យស្មិំ សមយេ អរូបូបបត្តិយា មគ្គំ ភាវេតិ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មិំ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ អរូបាវចរស្ស កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា វិបាកំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មិំ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៩០) ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។ បេ ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនមគ្គ ដើម្បីកើតក្នុងអរូបភព កន្លងអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះបង់សុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថាជាកុសល កន្លងអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះសុខផង ។ បេ ។ ចូលកាន់ចតុត្ថជ្ឈាន ជាវិបាក ព្រោះភាពនៃកម្មជាអរូបាវចរកុសលនោះឯង ដែលលោកធ្វើហើយ សន្សំហើយ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៨០) ឈាន ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។

(៤៨១) តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ បឋមាយ ភូមិយា បត្តិយា វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។ បេ ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៨២) តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ លោកុត្តរំ ឈានំ ភាវេតិ និយ្យានិកំ អបចយគាមឹ ទិដ្ឋិគតានំ បហានាយ

[៤៨១] បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ (នូវកម្មកិលេស) ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់នូវបឋមភូមិ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាទុក្ខាបដិបទាទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន ជាវិបាក ព្រោះភាពនៃឈានជាលោកុត្តរកុសលនោះឯងដែលលោកធ្វើហើយ អប់រំហើយ ជាទុក្ខាបដិបទាទន្ធាភិញ្ញា ជាសុញ្ញតៈ ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

[៤៨២] បណ្ដាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនលោកុត្តរជ្ឈាន ជានិយ្យានិកធម៌ ជាគ្រឿងដល់នូវការមិនសន្សំ ដើម្បីលះទិដ្ឋិទាំងឡាយ ដើម្បីដល់

បឋមាយ ភូមិយា បត្តិយា វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ តស្មឹ សមយេ ផស្សោ ហោតិ ។បេ។ អវិក្ខេបោ ហោតិ ឥមេ ធម្មា កុសលា តស្សេវ លោកុត្តរស្ស កុសលស្ស ឈានស្ស កតត្តា ភាវិតត្តា វិបាកំ វិតក្កវិចារានំ វូបសមា ។បេ។ បឋមំ ឈានំ ។បេ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ ទុក្ខាបដិបទំ ទន្ធាភិញ្ញំ សុញ្ញតំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៤៨៣) ចត្តារិ ឈានានិ បឋមំ ឈានំ ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ។

(៤៨៤) តត្ថ កតមំ បឋមំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ

នូវបឋមភូមិ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ជាទុក្ខាបដិបទា ទន្ធាភិញ្ញា ហើយសម្រាកនៅ ក្នុងសម័យនោះ ផស្សៈ ក៏កើតមាន ។ បេ ។ អវិក្ខេបៈ ក៏កើតមាន ធម៌ទាំងនេះ ឈ្មោះថា ជាកុសល ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។ បេ ។ ចូលកាន់បឋម-ជ្ឈាន ។ បេ ។ ចូលកាន់បញ្ចមជ្ឈាន ជាវិបាក ព្រោះភាពនៃឈាន ជាលោកុត្តរកុសលនោះឯង ដែលលោកធ្វើហើយ អប់រំហើយ ជាទុក្ខា-បដិបទា ទន្ធាភិញ្ញា ជាសុញ្ញតៈ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៨៣) ឈាន ៤ គឺ បឋមជ្ឈាន១ ទុតិយជ្ឈាន១ តតិ-យជ្ឈាន១ ចតុត្ថជ្ឈាន១ ។

(៤៨៤) បណ្ដាឈានទាំងនោះ បឋមជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលកាន់បឋមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ

តស្មឹ សមយេ បញ្ចង្គិកំ ឈានំ ហោតិ វិតក្កោ វិចារោ បីតិ សុខំ ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បឋមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

(៦៨៥) តត្ថ កតមំ ទុតិយំ ឈានំ ។ ឥធ ភិក្ខុ យស្មឹ សមយេ រូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានំ ។ បេ ។ បឋមំ ឈានំ ។ បេ ។ បញ្ចមំ ឈានំ ឧបសម្បជ្ជ វិហរតិ បឋវីកសិណំ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ បញ្ចមំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។ បេ ។ ឥធ ភិក្ខុ យស្មឹ សមយេ អរូបាវចរំ ឈានំ ភាវេតិ កិរិយំ នេវ កុសលំ នាកុសលំ ន ច កម្មវិបាកំ ទិដ្ឋធម្មសុខវិហារំ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនសញ្ញាសហគតំ សុខស្ស ច បហានា ។ បេ ។

ក្នុងសម័យនោះ ឈានមានអង្គ ៥ គឺ វិតក្កៈ វិចារៈ បីតិ សុខ ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បឋមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

(៤៨៥) បណ្ដាឈានទាំងនោះ ទុតិយជ្ឈាន តើដូចម្ដេច ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។ បេ ។ ចូលកាន់ទុតិយជ្ឈាន ។ បេ ។ តតិយជ្ឈាន ។ បេ ។ ចតុត្ថជ្ឈាន ។ បេ ។ បឋមជ្ឈាន ។ បេ ។ បញ្ចមជ្ឈាន មានបឋវីកសិណ (ជាអារម្មណ៍) ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមានអង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា បញ្ចមជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។ បេ ។ ក្នុងសម័យណា ភិក្ខុក្នុងសាសនានេះ ចំរើនអរូបាវចរជ្ឈាន ជាកិរិយា មិនមែនកុសល មិនមែនអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន កន្លងនូវអាកិញ្ចញ្ញាយតនៈ ដែលប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ដោយប្រការទាំងពួង ព្រោះលះសុខផង ។ បេ ។

ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ តស្មឹ សមយេ ទុវង្គិកំ ឈានំ ហោតិ ឧបេក្ខា ចិត្តស្ស ឯកគ្គតា ឥទំ វុច្ចតិ ចតុត្ថំ ឈានំ អវសេសា ធម្មា ឈានសម្បយុត្តា ។

## អភិធម្មភាជនីយំ ។

( ៥៨៦ ) ចត្តារិ ឈានានិ ឥធ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា

ចូលកាន់ចតុត្ថជ្ឈាន ហើយសម្រាកនៅ ក្នុងសម័យនោះ ឈានមាន អង្គ ២ គឺ ឧបេក្ខា ចិត្តេកគ្គតា ក៏កើតមាន នេះហៅថា ចតុត្ថជ្ឈាន ធម៌ទាំងឡាយដ៏សេស ក៏ឈ្មោះថា ប្រកបដោយឈាន ។

ចប់ **អភិធម្មភាជនីយ** ។

(៤៨៦) ឈាន ៤ គឺ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខកើតក្នុងវិវេក ភិក្ខុព្រោះរម្ងាប់វិតក្កៈនិងវិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាន ប្រកបដោយសេចក្ដីជ្រះថ្លាគឺសទ្ធា មានភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ ដែលកើតក្នុងសមាធិគឺបឋមជ្ឈាន ព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានសតិនិង សម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរ នូវបុគ្គលដែលព្រមព្រៀង ដោយតតិយជ្ឈាននោះថា បុគ្គល ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏ចូលកាន់តតិយជ្ឈាននោះ ព្រោះលះសុខផង ព្រោះលះទុក្ខផង

បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ចតុន្នំ ឈានានំ កតិ កុសលា កតិ អកុសលា កតិ អព្យាកតា ។បេ។ កតិ សរណា កតិ អរណា ។

(៤៨៧) សិយា កុសលា សិយា អព្យាកតា ។ តីណិ ឈានា ឯត្ថុប្បន្នំ សុខំ វេទនំ ឋបេត្វា សុខាយ វេទនាយ សម្បយុត្តា ចតុត្ថំ ឈានំ ឯត្ថុប្បន្នំ អទុក្ខមសុខំ វេទនំ ឋបេត្វា អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ។ សិយា វិបាកា សិយា វិបាកធម្មធម្មា សិយា នេវវិបាកនវិបាកធម្មធម្មា សិយា ឧបាទិន្នុបាទានិយា សិយា អនុបាទិន្នុបាទានិយា សិយា អនុបាទិន្នានុបាទានិយា សិយា អសង្កិលិដ្ឋសង្កិលេសិកា សិយា អសង្កិលិដ្ឋាសង្កិលេសិកា ។ បឋមំ ឈានំ ឯត្ថុប្បន្នេ វិតក្កវិចារេ ឋបេត្វា សវិតក្កសវិចារំ តីណិ ឈានា អវិតក្កាវិចារា ។

ព្រោះវិនាសទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង ហើយចូលកាន់ចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនទុក្ខមិនមែនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ។ បណ្ដាឈានទាំង ៤ ឈាន ជាកុសលប៉ុន្មាន ជាអកុសលប៉ុន្មាន ជាអព្យាក្រឹតប៉ុន្មាន ។បេ។ ជាសរណៈប៉ុន្មាន ជាអរណៈប៉ុន្មាន ។

(៤៨៧) ឈានជាកុសលក៏មាន ជាអព្យាក្រឹតក៏មាន ។ ឈាន ៣ ប្រកបដោយសុខវេទនា វៀរលែងតែសុខវេទនា ដែលកើតក្នុងឈាននុ៎ះចេញ ឈានទី ៤ ប្រកបដោយអទុក្ខមសុខវេទនា វៀរលែងតែអទុក្ខមសុខវេទនា ដែលកើតក្នុងឈាននុ៎ះចេញ ។ ឈាន ជាវិបាកក៏មាន មានវិបាកធម៌ជាប្រក្រតីក៏មាន មិនមែនជាវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតីក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទានក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យក តែជាប្រយោជន៍ដល់ឧបាទាន ក៏មាន មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមមិនកាន់យក ទាំងមិនជាប្រយោជន៍ដល់ឧបាទានក៏មាន មិនសៅហ្មងតែគួរដល់សេចក្ដីសៅហ្មងក៏មាន មិនសៅហ្មងទាំងមិនគួរដល់សេចក្ដីសៅហ្មងក៏មាន ។ ឈានទី ១ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ វៀរលែងតែវិតក្កៈនិងវិចារៈ ដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិតក្កៈ មិនមានវិចារៈ ។

ទ្វេ ឈានា ឧប្បន្នំ បីតឹ ឋបេត្វា បីតិសហគតា តីណិ ឈានា ឧប្បន្នំ សុខំ ឋបេត្វា សុខសហគតា ចតុត្ថំ ឈានំ ឧប្បន្នំ ឧបេក្ខំ ឋបេត្វា ឧបេក្ខាសហគតំ ។ នេវ ទស្សនេន ន ភាវនាយ បហាតព្វា នេវ ទស្សនេន ន ភាវនាយ បហាតព្វហេតុកា សិយា អាចយគាមិនោ សិយា អបចយគាមិនោ សិយា នេវាចយគាមិនោ នាបចយគាមិនោ សិយា សេក្ខា សិយា អសេក្ខា សិយា នេវ សេក្ខា នាសេក្ខា សិយា មហគ្គតា សិយា អប្បមាណា ។ តីណិ ឈានា ន វត្តព្វា បរិត្តារម្មណាតិបិ មហគ្គតារម្មណាតិបិ សិយា អប្បមាណារម្មណា សិយា ន វត្តព្វា អប្បមាណារម្មណាតិ ចតុត្ថំ ឈានំ សិយា បរិត្តារម្មណំ សិយា មហគ្គតារម្មណំ សិយា អប្បមាណារម្មណំ សិយា ន វត្តព្វំ បរិត្តារម្មណន្តិបិ មហគ្គតារម្មណន្តិបិ អប្បមាណារម្មណន្តិបិ ។ សិយា មជ្ឈិមា សិយា បណីតា សិយា សម្មត្តនិយតា សិយា អនិយតា ។

ឈា ២ ប្រឡំដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ ប្រឡំដោយសុខ វៀរលែងតែសុខដែលកើតក្នុងឈាននុ៎ះចេញ ឈានទី ៤ ប្រឡំដោយឧបេក្ខា វៀរលែងតែឧបេក្ខាដែលកើតក្នុងឈាននុ៎ះចេញ ។ ឈាន ដែលមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ទាំងមិនគួរលះដោយភាវនា ដល់នូវការសន្សំ ( នូវកម្មកិលេស ) ក៏មាន ដល់នូវការមិនសន្សំក៏មាន មិនដល់នូវការសន្សំ ទាំងមិនដល់នូវការមិនសន្សំក៏មាន ជារបស់សេក្ខបុគ្គលក៏មាន ជារបស់អសេក្ខបុគ្គលក៏មាន មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គលក៏មាន ដល់នូវសភាពធំក៏មាន មិនមានប្រមាណក៏មាន ។ ឈាន ៣ មិនគួរពោលថា មានអារម្មណ៍តូចផង ថា មានអារម្មណ៍ដល់នូវសភាពធំផងឡើយ មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគួរពោលថា មានអារម្មណ៍មិនមានប្រមាណក៏មាន ឈានទី ៤ មានអារម្មណ៍តូចឆ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍មិនមានប្រមាណក៏មាន មិនគួរពោលថា មានអារម្មណ៍តូចឆ្មារផង ថា មានអារម្មណ៍ដល់នូវភាពធំផង ថា មានអារម្មណ៍មិនមានប្រមាណផងក៏មាន ។ ឈានជាកណ្តាលក៏មាន ឧត្តមក៏មាន មានសភាពត្រូវនិងទៀងក៏មាន មានសភាពមិនទៀងក៏មាន

តីណិ ឈានា ន មគ្គារម្មណា សិយា មគ្គហេតុកា សិយា មគ្គាធិបតិនោ សិយា ន វត្តព្វា មគ្គហេតុកាតិបិ មគ្គាធិបតិនោតិបិ ចតុត្ថំ ឈានំ សិយា មគ្គារម្មណំ សិយា មគ្គហេតុកំ សិយា មគ្គាធិបតិ សិយា ន វត្តព្វំ មគ្គារម្មណន្តិបិ មគ្គហេតុកន្តិបិ មគ្គាធិបតីតិបិ ។ សិយា ឧប្បន្នា សិយា អនុប្បន្នា សិយា ឧប្បាទិនោ សិយា អតីតា សិយា អនាគតា សិយា បច្ចុប្បន្នា ។ តីណិ ឈានា ន វត្តព្វា អតីតារម្មណាតិបិ អនាគតារម្មណាតិបិ បច្ចុប្បន្នារម្មណាតិបិ ចតុត្ថំ ឈានំ សិយា អតីតារម្មណំ សិយា អនាគតារម្មណំ សិយា បច្ចុប្បន្នារម្មណំ សិយា ន វត្តព្វំ អតីតារម្មណន្តិបិ អនាគតារម្មណន្តិបិ បច្ចុប្បន្នារម្មណន្តិបិ ។ សិយា អជ្ឈត្តា សិយា ពហិទ្ធា សិយា អជ្ឈត្តពហិទ្ធា ។ តីណិ ឈានា ពហិទ្ធារម្មណា ចតុត្ថំ ឈានំ សិយា អជ្ឈត្តារម្មណំ សិយា ពហិទ្ធារម្មណំ សិយា អជ្ឈត្តពហិទ្ធារម្មណំ សិយា ន វត្តព្វំ អជ្ឈត្តារម្មណន្តិបិ ពហិទ្ធារម្មណន្តិបិ អជ្ឈត្តពហិទ្ធារម្មណន្តិបិ ។ អនិទស្សនាប្បដិឃា ។

ឈាន ៣ មិនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងក៏មាន ឈានទី ៤ មានមគ្គជាអារម្មណ៍ក៏មាន មានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគួរពោលថា មានមគ្គជាអារម្មណ៍ផង ថា មានមគ្គជាហេតុផង ថា មានមគ្គជាអធិបតីផងក៏មាន ។ ឈាន ដែលកើតហើយក៏មាន មិនទាន់កើតក៏មាន បម្រុងនឹងកើតក៏មាន ជាអតីតក៏មាន ជាអនាគតក៏មាន ជាបច្ចុប្បន្នក៏មាន ។ ឈាន ៣ មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងឡើយ ឈានទី ៤ មានអារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគួរពោលថា មានអារម្មណ៍ជាអតីតផង ថា មានអារម្មណ៍ជាអនាគតផង ថា មានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ ឈាន ខាងក្នុងក៏មាន ខាងក្រៅក៏មាន ទាំងខាងក្នុងទាំងខាងក្រៅក៏មាន ។ ឈាន ៣ មានអារម្មណ៍ខាងក្រៅ ឈានទី ៤ មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏មាន មានអារម្មណ៍ខាងក្នុងនិងខាងក្រៅក៏មាន មិនគួរពោលថា មានអារម្មណ៍ខាងក្នុងផង ថា មានអារម្មណ៍ខាងក្រៅផង ថា មានអារម្មណ៍ខាងក្នុងនិងខាងក្រៅផងក៏មាន ។ ឈាន មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

[ ៦៨៨ ] ន ហេតូ សហេតុកា ហេតុសម្បយុត្តា ន វត្តព្វា ហេតូ ចេវ សហេតុកា ចាតិ សហេតុកា ចេវ ន ច ហេតូ ន វត្តព្វា ហេតូ ចេវ ហេតុសម្បយុត្តា ចាតិ ហេតុសម្បយុត្តា ចេវ ន ច ហេតូ ន ហេតូ សហេតុកា ។ សប្បច្ចយា សង្ខតា អនិទស្សនា អប្បដិឃា អរូបា សិយា លោកិយា សិយា លោកុត្តរា កេនចិ វិញ្ញេយ្យា កេនចិ ន វិញ្ញេយ្យា ។ នោ អាសវា សិយា សាសវា សិយា អនាសវា អាសវវិប្បយុត្តា ន វត្តព្វា អាសវា ចេវ សាសវា ចាតិ សិយា សាសវា ចេវ នោ ច អាសវា សិយា ន វត្តព្វា សាសវា ចេវ នោ ច អាសវាតិ ន វត្តព្វា អាសវា ចេវ អាសវសម្បយុត្តា ចាតិបិ អាសវសម្បយុត្តា ចេវ នោ ច អាសវាតិបិ សិយា អាសវវិប្បយុត្តសាសវា សិយា អាសវវិប្បយុត្តអនាសវា ។ នោ សញ្ញោជនា ។បេ។

(៤៨៨) ពួកឈានមិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ប្រកបដោយហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រព្រឹត្តទៅជាមួយនឹងហេតុទេ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ មិនគួរពោលថា ជាហេតុ ទាំងប្រកបដោយហេតុឡើយ គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ គឺមិនមែនហេតុ គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ ៗ ពួកឈាន ប្រកបដោយបច្ច័យ ត្រូវបច្ច័យតាក់តែង មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់ ឥតរូប ជាលោកិយក៏មាន ជាលោកុត្តរក៏មាន ដែលបុគ្គលគប្បីដឹងដោយវិញ្ញាណណាមួយ ដែលបុគ្គលមិនគប្បីដឹងដោយវិញ្ញាណណាមួយក៏មាន ៗ ពួកឈាន មិនមែនអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន មិនមានអាសវៈ ទាំងប្រាសចាកអាសវៈ តែមិនគួរពោលថា ជាអាសវៈ ទាំងប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនអាសវៈក៏មាន មិនគួរពោលថា ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ក៏មាន មិនគួរពោលថា ជាអាសវៈ ទាំងប្រកបដោយអាសវៈផង ថា ប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងក៏មាន ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈក៏មាន ប្រាសចាកអាសវៈ ទាំងមិនមានអាសវៈក៏មាន ៗ ពួកឈាន មិនមែនសំយោជនៈ ៗ បេ ៗ

នោ គន្ថា ។បេ។ នោ ឱឃា ។បេ។ នោ យោគា ។បេ។ នោ នីវរណា ។បេ។ នោ បរាមាសា ។បេ។ សារម្មណា នោ ចិត្តា ចេតសិកា ចិត្តសម្បយុត្តា ចិត្តសំសដ្ឋា ចិត្តសមុដ្ឋានា ចិត្តសហភុនោ ចិត្តានុបរិវត្តិនោ ចិត្តសំសដ្ឋសមុដ្ឋានា ចិត្តសំសដ្ឋសមុដ្ឋានសហភុនោ ចិត្តសំសដ្ឋានានុបរិវត្តិនោ ពាហិរា ឧបាទា សិយា ឧបាទិន្នា សិយា អនុបាទិន្នា ។ ឧបាទានា ។បេ។ នោ កិលេសា ។បេ។

(៤៨៩) ន ទស្សនេន បហាតព្វា ន ភាវនាយ បហាតព្វា ន ទស្សនេន បហាតព្វហេតុកា ។ បឋមំ ឈានំ ឧប្បន្នំ វិតក្កំ ឋបេត្វា សវិតក្កំ តីណិ ឈានា អវិតក្កា ។ បឋមំ ឈានំ ឧប្បន្នំ វិចារំ ឋបេត្វា សវិចារំ តីណិ ឈានា អវិចារា ។ ទ្វេ ឈានា ឧប្បន្នំ បីតឹ ឋបេត្វា សប្បីតិកា ទ្វេ ឈានា អប្បីតិកា ។ ទ្វេ ឈានា ឧប្បន្នំ បីតឹ ឋបេត្វា បីតិសហគតា ទ្វេ ឈានា ន បីតិសហគតា ។

មិនមែនគន្ថៈ ។បេ។ មិនមែនឱឃៈ ។បេ។ មិនមែនយោគៈ ។បេ។ មិនមែននីវរណៈ ។បេ។ មិនមែនបរាមាសៈ ។បេ។ ពួកឈានប្រព្រឹត្តទៅជាមួយនឹងអារម្មណ៍ មិនមែនចិត្ត ជាចេតសិក ប្រកបដោយចិត្ត ប្រឡំដោយចិត្ត តាំងឡើងអំពីចិត្ត កើតជាមួយនឹងចិត្ត ប្រព្រឹត្តទៅតាមនូវចិត្ត ប្រឡំផងតាំងឡើងអំពីចិត្ត ប្រឡំផងតាំងឡើងផងកើតជាមួយនឹងចិត្ត ប្រឡំផងប្រព្រឹត្តទៅតាមចិត្ត ជាខាងក្រៅ មិនមែនឧបាទា មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយក៏មាន មិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយក៏មាន ។ ពួកឈាន មិនមែនឧបាទាន ។បេ។ មិនមែនកិលេស ។បេ។

(៤៨៩) ពួកឈានមិនគួរលះដោយទស្សនៈ មិនគួរលះដោយភាវនា មានហេតុមិនគួរលះដោយទស្សនៈ ។ ឈានទី ១ ប្រកបដោយវិតក្កៈ វៀរលែងតែវិតក្កៈដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិតក្កៈទេ ។ ឈានទី ១ ប្រកបដោយវិចារៈ វៀរលែងតែវិចារៈដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនមានវិចារៈទេ ។ ឈាន ២ ប្រកបដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈាននុ៎ះចេញ ឈាន ២ មិនមានបីតិទេ ។ ឈាន ២ ប្រឡំដោយបីតិ វៀរលែងតែបីតិដែលកើតក្នុងឈាននុ៎ះចេញ ឈាន ២ មិនប្រឡំដោយបីតិទេ ។

## ឈានវិភង្គេ បញ្ហាបុច្ឆកំ

តីណិ ឈានា ឧប្បជ្ជន្តិ សុខំ ឋបេត្វា សុខសហគតា ចតុត្ថំ ឈានំ ន សុខសហគតំ ។ ចតុត្ថំ ឈានំ ឧប្បជ្ជន្តិ ឧបេក្ខំ ឋបេត្វា ឧបេក្ខាសហគតំ តីណិ ឈានា ន ឧបេក្ខាសហគតា ។ ន កាមាវចរា សិយា រូបាវចរា សិយា ន រូបាវចរា ។ តីណិ ឈានា ន អរូបាវចរា ចតុត្ថំ ឈានំ សិយា អរូបាវចរំ សិយា ន អរូបាវចរំ ។ សិយា បរិយាបន្នា សិយា អបរិយាបន្នា សិយា និយ្យានិកា សិយា អនិយ្យានិកា សិយា និយតា សិយា អនិយតា សិយា សឧត្តរា សិយា អនុត្តរា អរណាតិ ។

បញ្ហាបុច្ឆកំ ។

ឈានវិភង្គោ សមត្តោ ។

ឈានវិភង្គ បញ្ហាបុច្ឆកៈ

ឈាន ៣ ប្រកបដោយសុខ វៀរលែងតែសុខដែលកើតក្នុងឈាននុ៎ះចេញ ឈានទី ៤ មិនប្រកបដោយសុខទេ ។ ឈានទី ៤ ប្រកបដោយឧបេក្ខា វៀរលែងតែឧបេក្ខាដែលកើតក្នុងឈាននុ៎ះចេញ ឈាន ៣ មិនប្រកបដោយឧបេក្ខាទេ ។ ពួកឈានមិនមែនជាកាមាវចរ តែជារូបាវចរក៏មាន មិនមែនរូបាវចរក៏មាន ។ ឈាន ៣ មិនមែនអរូបាវចរ ឈានទី ៤ ជាអរូបាវចរក៏មាន មិនមែនអរូបាវចរក៏មាន ។ ពួកឈាន ជាបរិយាបន្នៈក៏មាន ជាអបរិយាបន្នៈក៏មាន ជានិយ្យានិកៈក៏មាន ជាអនិយ្យានិកៈក៏មាន ជានិយតៈក៏មាន ជាអនិយតៈក៏មាន ជាសឧត្តរៈក៏មាន ជាអនុត្តរៈ ជាអរណៈក៏មាន ។

ចប់ បញ្ហាបុច្ឆកៈ ។

ចប់ ឈានវិភង្គ ។

# អប្បមញ្ញាវិភង្គោ

[៦៩០] ចតស្សោ អប្បមញ្ញាយោ ។ ឥធ ភិក្ខុ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ករុណាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ មុទិតាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ

# អប្បមញ្ញាវិភង្គ

(៦៩០) អប្បមញ្ញា ៤ យ៉ាង ។ គឺ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយករុណា ដ៏ធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុ មានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច

សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មុទិតាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថឹ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។

(៤៩១) កថញ្ច ភិក្ខុ មេត្តាសហគតេន ចេតសោ ឯកំ ទិសំ ផរិត្វា វិហរតិ ។ សេយ្យថាបិ នាម ឯកំ បុគ្គលំ បិយំ មនាបំ ទិស្វា មេត្តាយេយ្យ ឯវមេវ សព្វេ សត្តេ មេត្តាយ ផរតិ ។

(៤៩២) តត្ថ កតមា មេត្តា ។ យា សត្តេសុ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា ។ តត្ថ កតមំ ចិត្តំ ។

មានចិត្តប្រកបដោយមុទិតា ដ៏ធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។ ភិក្ខុ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូច មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំ ទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង ហើយសម្រាកនៅ ១ ។

(៤៩១) ចុះភិក្ខុមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គលឃើញបុគ្គលម្នាក់ ជាទីស្រឡាញ់ ជាទីពេញចិត្ត គប្បីផ្សាយមេត្តា យ៉ាងណា ភិក្ខុរមែងផ្សាយមេត្តា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

(៤៩២) បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោ-វិមុត្តិ (ការរួចស្រឡះចាកព្យាបាទដោយអំណាចចិត្ត) ណា ចំពោះពួកសត្វ នេះហៅថា មេត្តា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។

យំ ចិត្តំ មនោ មានសំ ហទយំ បណ្ឌរំ មនោ
មនាយតនំ មនិន្ទ្រិយំ វិញ្ញាណំ វិញ្ញាណក្ខន្ធោ តជ្ជា
មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ
ឥមាយ មេត្តាយ សហគតំ ហោតិ សហជាតំ
សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ មេត្តាសហគតេន
ចេតសាតិ ។ ឯកំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ
វា ទិសំ ឧត្តរំ វា ទិសំ ទក្ខិណំ វា ទិសំ
ឧទ្ធំ វា អធោ វា តិរិយំ វា វិទិសំ វា ។ ផរិត្វាតិ
ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ វត្តតិ បា-
លេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ
វិហរតីតិ ។ តថា ទុតិយន្តិ យថេវ ឯកំ ទិសំ
តថា ទុតិយំ ទិសំ តថា តតិយំ ទិសំ តថា
ចតុត្ថំ ទិសំ តថា ឧទ្ធំ តថា អធោ តថា តិរិយំ
តថា វិទិសំ ។ សព្វធិ សព្វត្តតាយ សព្វាវន្តំ
លោកន្តិ សព្វេន សព្វំ សព្វថា សព្វំ អសេ-
សំ និស្សេសំ បរិយាទាយ វចនមេតំ សព្វធិ

ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហទយៈ បណ្ឌរៈ (ធម្មជាតដ៏ផូរផង់) មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណ-ធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំគ្នា ប្រកបព្រមដោយមេត្តានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមេត្តា ។ ពាក្យថា ទិស ១ គឺ ទិសខាងកើតក្តី ទិសខាងលិចក្តី ទិសខាងជើងក្តី ទិសខាងត្បូងក្តី ទិសខាងលើក្តី ទិសខាងក្រោមក្តី ទិសទទឹងក្តី ទិសផ្សេងៗក្តី ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺ ផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេង ៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង មានសេចក្តីថា ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វទាំងអស់ ក្នុងទីទាំងពួង នុះជាពាក្យរបស់សត្វទាំងពួង ទាំងអស់ ពល់រូប គ្រប់រូប

សព្វត្តតាយ សព្វាវន្តំ លោកន្តិ ។ មេត្តាសហគតេន ចេតសាតិ តត្ថ កតមា មេត្តា ។ យា សត្តេសុ មេត្តិ មេត្តាយនា មេត្តាយិតត្តំ មេត្តា ចេតោវិមុត្តិ អយំ វុច្ចតិ មេត្តា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ មេត្តាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ មេត្តាសហគតេន ចេតសាតិ ។ វិបុលេនាតិ យំ វិបុលំ តំ មហគ្គតំ យំ មហគ្គតំ តំ អប្បមាណំ យំ អប្បមាណំ សោ អវេរោ យោ អវេរោ សោ អព្យាបជ្ជោ ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

(៦៩៣) កថញ្ច ភិក្ខុ ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ សេយ្យថាបិ នាម ឯកំ បុគ្គលំ ទុគ្គតំ ទុរូបេតំ ទិស្វា ករុណាយេយ្យ ឯវមេវ សព្វេ សត្តេ ករុណាយ ផរតិ ។

មិនមានសល់ ឥតសេសសល់ ។ ពាក្យថា មានចិត្តប្រកបដោយ មេត្តា សេចក្តីថា បណ្តាអប្បមញ្ញាទាំងនោះ មេត្តា តើដូចម្តេច ។ ការរាប់អាន អាការរាប់អាន ភាពនៃការរាប់អាន ការរាប់រក ចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា មេត្តា ។ បណ្តាធម៌ទាំងនោះ ចិត្ត តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាជ្ញា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ប្រឡំគ្នា ប្រកបព្រម ដោយមេត្តានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយមេត្តា ។ ពាក្យថា ទូលាយ គឺ គុណជាតណា ដ៏ទូលាយ គុណជាតនោះ ដល់នូវភាពជាធំ គុណជាតណា ដល់នូវភាពជាធំ គុណជាតនោះ មិនមានប្រមាណ គុណជាតណា មិនមានប្រមាណ សភាវៈនោះ មិនមានពៀរ សភាវៈណា មិនមានពៀរ សភាវៈនោះ មិនមានព្យាបាទ ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជូនចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ។ បេ ។ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។

(៤៩៣) ចុះភិក្ខុ មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិស ១ តើដូចម្តេច ។ បុគ្គល ឃើញបុគ្គលម្នាក់ ជាអ្នកក្រីក្រ ដល់នូវសេចក្តីលំបាក ហើយផ្សាយករុណា យ៉ាងណា ភិក្ខុផ្សាយករុណា ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះឯង ។

[៦៩៨] តត្ថ កតមា ករុណា ។ យា សត្តេសុ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។បេ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ ករុណាយ សហគតំ ហោតិ សហ-ជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ ករុណា-សហគតេន ចេតសាតិ ។ ឯកំ ទិសន្តិ បុរត្ថិមំ វា ទិសំ បច្ឆិមំ វា ទិសំ ឧត្តរំ វា ទិសំ ទក្ខិណំ វា ទិសំ ឧទ្ធំ វា អធោ វា តិរិយំ វា វិទិសំ វា ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ វត្តតិ បាលេតិ យបេតិ យាបេតិ ចរតិ វិហរតិ តេន វុច្ចតិ វិហរ-តីតិ ។ តថា ទុតិយន្តិ យថេវ ឯកំ ទិសំ តថា ទុតិយំ ទិសំ តថា តតិយំ ទិសំ តថា ចតុត្ថំ ទិសំ តថា ឧទ្ធំ តថា អធោ តថា តិរិយំ តថា វិទិ-សំ ។ សព្ពធិ សព្ពត្តតាយ សព្ពាវន្តំ លោកន្តិ

[៤៩៤] បណ្ដាធម៌ទាំងនោះ ករុណា តើដូចម្ដេច ។ ការអាណិត អាការអាណិត ភាពនៃការអាណិត ការអាណិតអាសូរចេតោវិមុត្តិ ណា ចំពោះពួកសត្វ នេះហៅថា ករុណា ។ បណ្ដាធម៌ទាំងនោះ ចិត្ត តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាជ្ញា ។ បេ ។ មនោវិញ្ញាណធាតុ ដែលកើតអំពីវិញ្ញាណនោះ ណា នេះហៅថា ចិត្ត ។ ចិត្តនេះ ជាធម្មជាតទៅជាមួយគ្នា កើតជាមួយគ្នា ប្រឡំគ្នា ប្រកបព្រម ដោយករុណានេះ ព្រោះហេតុនោះ ទើបពោលថា មានចិត្តប្រកបដោយករុណា ។ ពាក្យថា ទិស ១ គឺ ទិសខាងកើតក្ដី ទិសខាងលិចក្ដី ទិសខាងជើងក្ដី ទិសខាងត្បូងក្ដី ទិសខាងលើក្ដី ទិសខាងក្រោមក្ដី ទិសទទឹងក្ដី ទិសផ្សេងៗក្ដី ។ ពាក្យថា ផ្សាយ គឺ ផ្សាយចិត្តទៅ បញ្ជានចិត្តទៅ ។ ពាក្យថា សម្រាកនៅ គឺ សម្រេចឥរិយាបថ ប្រព្រឹត្ត រក្សា រស់នៅ ញុំាងជីវិតឲ្យរស់នៅ ត្រាច់ទៅ សម្រាន្តនៅ ព្រោះហេតុនោះ ទើបពោលថា សម្រាកនៅ ។ ពាក្យថា ទិសទី ២ ក៏ដូចគ្នា គឺ ផ្សាយចិត្តទៅកាន់ទិស ១ យ៉ាងណា ផ្សាយចិត្តទៅកាន់ទិសទី ២ ទិសទី៣ ទិសទី ៤ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ទិសផ្សេង ៗ ក៏យ៉ាងនោះដែរ ។ ពាក្យថា ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនទៅប្រៀបផ្ទឹមនឹងសត្វលោកទាំងអស់ ក្នុងទីទាំងពួង

សព្វេន សព្វំ សព្វថា សព្វំ អសេសំ និស្សេសំ បរិយាទាយ វចនមេតំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកន្តិ ។ ករុណាសហគតេន ចេតសាតិ តត្ថ កតមា ករុណា ។ យា សត្តេសុ ករុណា ករុណាយនា ករុណាយិតត្តំ ករុណា ចេតោវិមុត្តិ អយំ វុច្ចតិ ករុណា ។ តត្ថ កតមំ ចិត្តំ ។ យំ ចិត្តំ មនោ មានសំ ។ បេ ។ តជ្ជា មនោវិញ្ញាណធាតុ ឥទំ វុច្ចតិ ចិត្តំ ។ ឥទំ ចិត្តំ ឥមាយ ករុណាយ សហគតំ ហោតិ សហជាតំ សំសដ្ឋំ សម្បយុត្តំ តេន វុច្ចតិ ករុណាសហគតេន ចេតសាតិ ។ វិបុលេនាតិ យំ វិបុលំ តំ មហគ្គតំ យំ មហគ្គតំ តំ អប្បមាណំ យំ អប្បមាណំ សោ អវេរោ យោ អវេរោ សោ អព្យាបជ្ជោ ។ ផរិត្វាតិ ផរិត្វា អធិមុច្ចិត្វា ។ វិហរតីតិ ឥរិយតិ ។ បេ ។ វិហរតិ តេន វុច្ចតិ វិហរតីតិ ។

